## សៀវភៅណែនាំ

# បច្ចេកទេសដំណាំបន្លែ






## អគ្គនាយកដ្ឋានកសិកម្ម

រៀបចំដោយ ៖ ក្រុមការងារនាយកដ្ឋានសាកវប្បកម្មនិងដំណាំរួមផ្សំ

# មាតិកា

**ចំណងជើង** **ទំព័រ**

សេចក្តីសង្ខេប ..........................................................................................................១
សេចក្តីផ្តើម ..........................................................................................................២

ដំណាំត្រកួន ..........................................................................................................៣

ដំណាំឪឡឹក ..........................................................................................................១០

ដំណាំត្រប់ ..........................................................................................................១៦

ដំណាំល្ពៅ ..........................................................................................................២១

ដំណាំត្រសក់ចំណារ ..........................................................................................................២៧

ដំណាំស្ពៃចង្កឹះ ..........................................................................................................៣៦

# សេចក្តីសង្ខេប

សៀវភៅដំណាំបន្លែនេះត្រូវបានរៀបចំឡើងលើដំណាំបន្លែសំខាន់ៗចំនួន៦មុខរួមមានស្ពៃចង្កឹះ ឪឡឹក ត្រប់ ត្រសក់ចំណារ ល្ពៅ និងត្រកួន ដែលកសិករនិយមចូលចិត្ត និងងាយស្រួលដាំដុះ។

សៀវភៅនេះនឹងជួយដោះស្រាយបញ្ហាប្រជាកសិករភាគច្រើនដែលមិនបានរៀបចំគ្រប់គ្រងសួនបន្លែគ្រួសារបាន ត្រឹមត្រូវ ខ្វះបច្ចេកទេសដាំដុះ និងវិធានការការពារគ្រប់គ្រងលើកត្តាចង្រៃត្រឹមត្រូវ។

គោលដៅសំខាន់នៃសៀវភៅនេះគឺដើម្បីបង្កើនផលិតកម្ម និងអាហារូបត្ថម្ភគ្រប់រដូវកាលដោយពុំប៉ះពាល់សុខភាព កាត់បន្ថយការចំណាយពេលវេលា និងថវិកាគ្រួសារ។

សៀវភៅនេះក៏បានផ្តល់នូវវិធីសាស្រ្ត និងបច្ចេកទេសដាំដុះថ្មីៗងាយៗទាក់ទងទៅនឹងប្រភេទបន្លែ ដែលកសិករនិយមដាំដុះក្នុងសួនបន្លែគ្រួសារដែលមានផ្ទៃដីតូចៗនៅក្បែរផ្ទះ។ សៀវភៅនេះក៏បានណែនាំអំពីរបៀបប្រើប្រាស់ជីគីមី និងជីធម្មជាតិងាយៗ ពិសេសគឺរបៀបផលិតជីកំប៉ុស្តទឹក និងជីកំប៉ុស្តគោក ដែលវត្ថុធាតុដើមងាយរកក្នុងមូលដ្ឋានដូចជាកាកសំណល់ពីផ្ទះបាយ សួនបន្លែ លាមកសត្វ និងរុក្ខជាតិបៃតងជុំវិញភូមិ ដើម្បីកែប្រែគុណភាពដី និងមិនប៉ះពាល់ដល់បរិស្ថានជុំវិញ។

ម្យ៉ាងទៀតសៀវភៅនេះក៏បានចូលរួមចំណែកជាប្រយោជនិសម្រាប់មន្ត្រីផ្សព្វផ្សាយយកទៅប្រើ ប្រាស់ក្នុងការចូលរួមដោះស្រាយបញ្ហាចំពោះមុខលើការដាំដុះដំណាំបន្លែ ដែលកសិករកំពុងជួបប្រទះក្នុងការងារផលិតកម្មកសិកម្ម ពិពិធកម្មកសិកម្ម ដើម្បីធានាសន្តិសុខស្បៀង និងបង្កើនប្រាក់ចំណូលគ្រួសារ ជាពិសេសរួមចំណែកកាត់បន្ថយភាពក្រីក្រ ស្របតាមយុទ្ធសាស្រ្តចតុកោនរបស់រាជរដ្ឋាភិបាល។

# សេចក្ដីផ្ដើម

ការដាំដុះបន្លែភាគច្រើននៅស្រុកយើងគឺសម្រាប់តែការប្រើប្រាស់ក្នុងគ្រួសារ ប៉ុន្តែជារឿយៗ ការដាំដុះនេះបានផ្ដល់អោយបរិមាណផលទាបជាងតម្រូវការក្នុងគ្រួសារ។ ការដាំដុះបន្លែល្អបំផុតគឺនៅរដូវប្រាំងចាប់ពីខែវិច្ឆិកា-កុម្ភៈ និងដើមរដូវវស្សា។ ក្នុងអំឡុងពេលនេះ យើងអាចរកឃើញលក្ខខណ្ឌដាំដុះអនុគ្រោះបំផុតដូចជាសីតុណ្ហភាពទាប ការបំផ្លាញមានកំរិតទាប ដីមានសំណើមល្អ និងងាយរកប្រភពទឹកស្រោចស្រព។ បច្ចុប្បន្នការអភិវឌ្ឍនិដំណាំបន្លែនៅមានកំរិត ដែលអាចបណ្ដាលមកពីមូលហេតុមួយចំនួនដូចខាងក្រោម៖

- អត្រានៃការប្រើប្រាស់បន្លែនៅមានកំរិតទាប និងមិនទាន់មានការផ្លាស់ប្ដូរទម្លាប់ហូបចុកបន្លែអោយបានច្រើន
- មានការប្រកួតប្រជែងខ្ពស់ជាមួយបន្លែដែលនាំចូលពីប្រទេសជិតខាង
- ដីភាគច្រើនជាដីល្បាយខ្សាច់ មានសមត្ថភាពស្តុកទឹកខ្សោយ និងមានសារធាតុសរីរាង្គទាប លើកលែងតែដីទំនាបមាត់បឹងទន្លេសាប និងដីល្បប់តាមដងទន្លេមេគង្គនិងតាមដងស្ទឹងព្រែកនានា។
- ការផ្សព្វផ្សាយចំណេះដឹង និងការផ្ទេរបច្ចេកវិជ្ជាថ្មីៗដល់មូលដ្ឋានកសិករនៅមានកំរិតទាបនៅឡើយ
- ពុំទាន់មានប្រភពទឹក និងប្រព័ន្ធស្រោចស្រពគ្រប់គ្រាន់ ពិសេសនៅរដូវប្រាំង
- ប្រព័ន្ធពត៌មានទីផ្សារ និងខ្សែសង្វាក់ផលិតកម្មមិនទាន់រលូនរវាងប្រតិបត្តករទាំងអស់ ដែលរួមមានកសិករ អ្នកប្រមូលទិញ អ្នកលក់ដុំ អ្នកលក់រាយ ពាណិជ្ជករនាំចេញ-ចូល និងអ្នកផ្គត់ផ្គង់ធាតុចូលកសិកម្ម។
- ការអប់រំ និងការផ្សព្វផ្សាយបច្ចេកវិជ្ជាក្រោយពេលប្រមូលផលនិងការកែច្នៃបឋមនៅមានកំរិត
- ការប្រើប្រាស់ជី និងថ្នាំកសិកម្មមិនទាន់សមស្របតាមលក្ខណៈបច្ចេកទេស។

បញ្ហាទាំងនេះអាចដោះស្រាយបានតាមរយៈកិច្ចខិតខំប្រឹងប្រែងរួមគ្នារវាងអ្នកស្រាវជ្រាវ អ្នកបច្ចេកទេស អ្នកផ្សព្វផ្សាយ កសិករ និងប្រតិបត្តករទាំងអស់ក្នុងសង្វាក់ផលិតកម្មបន្លែ។ ដូច្នេះដើម្បីអោយមានការលើកកម្ពស់ជីវភាពរស់នៅល្អប្រសើរ និងប្រាក់ចំណូលគ្រួសារសមរម្យ កាត់បន្ថយបាននូវចំណាកស្រុក មានតែការខិតខំប្រឹងប្រែងលើការងារកសិកម្មដាំដុះនិងចិញ្ចឹមសត្វ ដោយប្រើប្រាស់អោយអស់លទ្ធភាពនូវប្រភពធនធានដែលមានស្រាប់ក្នុងតំបន់ ព្រមទាំងការជួយគាំទ្រទាំងសម្ភារៈ ស្មារតី និងបច្ចេកទេសដល់កសិករ។

# ការដាំត្រកួន

## ១. លក្ខណៈទូទៅរបស់ត្រកួន

ត្រកួនជារុក្ខជាតិត្រូវការពន្លឺថ្ងៃនិងទឹកគ្រប់គ្រាន់។ វាអាចដុះលូតលាស់លើដីគ្រប់ប្រភេទ ជាពិសេសដីល្បាយខ្សាច់ដែលមានជីជាតិ។ យើងអាចដាំវាបានគ្រប់រដូវទាំងនៅលើដី និងក្នុងទឹក។

**តើមានហេតុផលល្អៗអ្វីខ្លះដែលនាំឲ្យយើងដាំត្រកួន?**

១- មានជីវជាតិច្រើនសម្រាប់ចិញ្ចឹមរាងកាយ

២-ងាយស្រួលដាំថែទាំនិងងាយស្រួលលក់នៅទីផ្សារ

៣-ឆាប់បានប្រមូលផលនិងប្រមូលផលបានច្រើនដង

៤-អាចដាំដុះបានលើផ្ទៃដីគ្រប់ប្រភេទ និងគ្រប់រដូវឲ្យតែមានទឹកគ្រប់គ្រាន់

៥-ដើម ស្លឹកយកទៅធ្វើម្ហូបបានច្រើនមុខនិងមានរសជាតិឆ្ងាញ់សម្រាប់មនុស្សនិងអាចធ្វើជាចំណីសត្វ (ជ្រូកមាន់)។

៦-ងាយស្រួលក្នុងការថែរក្សាទុកគ្រាប់ពូជ។

**តើត្រកួនមានសារធាតុអ្វីខ្លះ?**

**វីតាមីនសេ** :ជួយរក្សាធ្មេញនិងអញ្ចាញធ្មេញឲ្យមានសុខភាពល្អ។បង្កើនសមត្ថភាពទប់ទល់ឬភាពស៊ាំនឹងជម្ងឺផ្សេងៗ

**វីតាមីនបេ** :ជួយឲ្យសរសៃប្រសាទដំណើរការនិងបង្កើនការរំលាយអាហារ។

**វីតាមីនអា** :ជួយឲ្យភ្នែកភ្លឺមើលឃើញបានច្បាស់ល្អ។

**ជាតិដែក** : ជួយក្នុងការបង្កើតគ្រាប់ឈាមក្រហម ជាពិសេសស្ត្រីមានផ្ទៃពោះត្រូវញ៉ាំត្រកួនឲ្យបានច្រើន។

**ប្រូតេអ៊ីន** :ជួយដល់ការលូតលាស់ខាងរាងកាយជាពិសេសសាច់ដុំ។

**កាល់ស្យូម** :ជាសារធាតុរ៉ែសម្រាប់ជួយឲ្យឆ្អឹងនិងធ្មេញរឹងមាំ ។

## ២.ការរៀបចំរងត្រកួន

ចង់ឲ្យត្រកួនដុះលូតលាស់បានល្អ យើងត្រូវរើសទីកន្លែងដាំ និងធ្វើរងឲ្យបានត្រឹមត្រូវស្របតាមរដូវនីមួយៗ។

## ៣.ការជ្រើសរើសទីកន្លែងដាំ

ការជ្រើសរើសទីកន្លែងដាំជាការសំខាន់បំផុតដើម្បីជៀសផុតពីការខូចខាត និងដើម្បីទទួលផលបានច្រើន ។

**<u>រដូវប្រាំង</u>** :ជ្រើសរើសទីកន្លែងដាំជិតប្រភពទឹក ដើម្បីងាយស្រួលក្នុងការស្រោចស្រព។

**<u>រដូវវស្សា</u>** :ជ្រើសរើសទីកន្លងដាំនៅលើដីទួលខ្ពស់មិនលិចទឹក ។

***អ្នកដាំឆ្ងួរដឹង***: *ត្រកួនគោកអាចដាំបានគ្រប់រដូវ ឲ្យតែដីធូរមានជីជាតិ និងមានទឹកគ្រប់គ្រាន់។*

## ៤.ការធ្វើរងដាំ

- ឧបករណ៍រៀបចំដី និងជីទ្រាប់បាតរង  - ចបជីក ចបកាប់  - រនាស់ដៃបង្គី

- ខ្សែម៉ែត្រ  - បង្គោលចុងស្រួច   - ជីកំប៉ុស្ត ជីលាមកសត្វ






### ៤.១.ការធ្វើរងដាំនៅរដូវវស្សា

១-កាប់ដីហាលរយៈពេល១០ថ្ងៃ ទុកឲ្យស្ងួត ទើបវាយបំបែកដីឲ្យម៉ដ្ឋ ។

២-លើករងត្រកួនដែលមានទទឹង១ម៉ែត្រកំពស់១តឹកកន្លះទៅ២តឹក ឯបណ្ដោយអាស្រ័យទៅតាមស្ថានភាពដីវែងឬខ្លី។

**ហេតុអ្វីត្រូវលើករងឲ្យខ្ពស់នៅរដូវវស្សា?**

ដើម្បីការពារទឹកដក់ ឬលិចរង ពេលមានភ្លៀងធ្លាក់ជោកជាំ ។

### ៤.២.ការធ្វើរងដាំនៅរដូវប្រាំង

១-កាប់ដីហាលតែរយៈពេល១អាទិត្យ បន្ទាប់មកវាយបំបែកដីឲ្យម៉ដ្ឋ។

២-លើករងដាំដែលមានទទឹង១ម៉ែត្រ កំពស់១តឹក និងបណ្ដោយអាស្រ័យទៅតាមស្ថានភាពដីវែង ឬខ្លី ។

## ៥.ការដាក់ជីទ្រាប់បាត

១-យកដីកំប៉ុស្ត ឬជីលាមកសត្វផ្សេងៗ ដែលពុកផុយមករោយពីលើរង។

២-យកចបកាប់មកជ្រំៗដី ត្រឡប់សារចុះ សារឡើង ដើម្បីឲ្យជីចូលទៅក្នុងដី។

៣-យករនាស់ដៃមករាស់ដីឲ្យបានស្មើល្អ ។

**<u>អ្នកដាំឆ្ងួរដឹង</u>**

*-ត្រូវរោយជីកំប៉ុស្ត ឬជីអាចម៍គោដែលពុកផុយ ចំនួនពី ៣ ទៅ៥គីឡូនៅលើដីមួយម៉ែត្របួនជ្រុង ។*

*-មិនត្រូវយកជីកំប៉ុស្តទៅចាក់គរទុកចោលនៅលើរង   ដោយមិនជ្រំត្រឡប់នោះទេ   ព្រោះវាធ្វើឲ្យសារធាតុចិញ្ចឹមនៅក្នុងជីហើរទៅតាមខ្យល់។*

ដើម្បីឲ្យគ្រាប់ពូជដុះបានល្អ យើងត្រូវយកគ្រាប់ពូជណាដែលគ្មានជម្ងឺ គ្មានការបំផ្លាញពីសត្វល្អិតនិងមិនទុកយូរឆ្នាំ។

## ៦.ការរៀបចំគ្រាប់ពូជ

### សម្ភារៈសម្រាប់បណ្ដុះ និងវត្ថុធាតុដើមសម្រាប់ដាំ

កូនឈើសម្រាប់ឆូតរងដាំ  ចង្អេរចានដែកក្រណាត់សម្រាប់ខ្ចប់គ្រាប់ពូជត្រកួនកំទេចចំបើង។






## ៧.របៀបបណ្ដុះ

១-យកគ្រាប់ពូជមកអុំរោយ និងរើសកំទេចកំទីសំរាមចោល។

២-ដាក់គ្រាប់ពូជសំដិលហាលថ្ងៃស្រទន់រយៈពេល១ទៅ២ម៉ោង ដើម្បីសម្លាប់មេរោគដែលនៅជាប់នឹងគ្រាប់។

៣-ត្រាំគ្រាប់ពូជក្នុងទឹករយៈពេល១២ម៉ោង(១យប់)។

៤-ស្រង់គ្រាប់ពូជ រួចយកក្រណាត់មកខ្ចប់ និងជ្រើមទឹកឲ្យសើមៗជានិច្ច។ ផ្អាប់ទុកពី១ទៅ២យប់ ដើម្បីឲ្យគ្រាប់ដុះពន្លកទើបយកទៅដាំ ។





**<u>អ្នកដាំគួដឹង</u>**

*ត្រូវហាលគ្រាប់ពូជនៅពេលថ្ងៃស្រទន់គឺចន្លោះពីម៉ោង៨ ដល់ម៉ោង១១ព្រឹក។ ហាលគ្រាប់ពូជនៅក្រោមថ្ងៃក្ដៅខ្លាំងធ្វើឲ្យគ្រាប់ពូជឆ្អិនពេក ជាហេតុនាំឲ្យគ្រាប់មិនដុះ។*

## ៨.ការសាបគ្រាប់ ឬការដាំ

ឆូតកូនចង្អូរកាត់ទទឹងរងជំរៅ១សង់ទីម៉ែត្រនៅរដូវប្រាំង និង២សង់ទីម៉ែត្រនៅរដូវវស្សា ។

__របៀបដាំ__

១-ឆូតរងដាំដោយទុកចន្លោះពីចង្អូរមួយទៅចង្អូរមួយចម្ងាយកន្លះតឹក នៅរដូវប្រាំង និង១តឹកនៅរដូវវស្សា។

២-រោយគ្រាប់ដោយទុកចន្លោះពីគ្រាប់១ទៅ១ ប្រវែងមួយសង់ទីម៉ែត្រនៅរដូវប្រាំង និងប្រវែង២សង់ទីម៉ែត្រនៅរដូវវស្សា។





__អ្នកជាំគួរដឹង__

*រោយគ្រាប់តាមកូនចង្អូរឲ្យស្មើល្អ។នៅលើផ្ទៃដីមួយម៉ែត្របួនជ្រុងត្រូវប្រើគ្រាប់អស់ចំនួន៥ក្រាម ។ ក្រោយពីរោយគ្រាប់ត្រកួនរួច ត្រូវយកកំទេចចំបើង ឬកំទេចស្លឹកឈើគ្របពីលើដើម្បីការពារកុំឲ្យហួតសំណើម ។*

## ៩.ការថែទាំមុនពេលប្រមូលផល

ដំណាំត្រកួនមិនពិបាកថែទាំទេ គឺយើងគ្រាន់តែដកស្មៅ ស្រោចជី និងស្រោចទឹកឲ្យបានគ្រប់គ្រាន់ប៉ុណ្ណោះ។

## ១០.ការស្រោចទឹក និងការធ្វើស្មៅ

ដំណាំត្រកួនត្រូវការទឹកច្រើន។ប្រសិនបើខ្វះទឹក ដើមត្រកួនលូតលាស់មិនបានល្អទេ វាក្រិន ឬរីង ។

-នៅរដូវប្រាំងក្រោយពីដាំហើយ យើងត្រូវស្រោចទឹកឲ្យជោកមួយថ្ងៃ២ដង(ព្រឹក និងល្ងាច)។

-ជ្រំដីនិងដកស្មៅជុំវិញគល់ត្រកួនឲ្យបានញឹកញាប់ក្រោយពីត្រកួនដុះបានរយៈពេលពី៤ទៅ៥ថ្ងៃ ព្រោះក្នុងរយៈពេលនេះស្មៅកំពុងដុះលូតលាស់ប្រជែងជាមួយត្រកួនដែរ ។

__អ្នកជាំគួរដឹង__

*នៅរដូវវស្សាយើងមិនបាច់ស្រោចទឹកទេ។ប្រសិនបើមានភ្លៀងដក់ទឹកច្រើនត្រូវបង្ហូរទឹកចេញពីរង។ការជ្រំដីនិងការធ្វើស្មៅធ្វើឲ្យដីធូរងាយជ្រាបទឹក ខ្យល់ចេញចូលបានស្រួល និងធ្វើឲ្យត្រកួនដុះបានល្អ ហើយមានដើមធំខ្លី។*

## ១១.ការធ្វើជីទឹក និងការស្រោចជីទឹក

ត្រកួនក៏ដូចជាដំណាំផ្សេងទៀតដែរ ដែលត្រូវការជីសម្រាប់បំប៉នបន្ថែម ដើម្បីឲ្យកាន់តែដុះលូតលាស់ល្អ។

__ឧបករណ៍និងវត្ថុធាតុដើមសម្រាប់ធ្វើជីទឹក__

-ពាងសម្រាប់ត្រាំជី-ឫស្សី ឬឈើសម្រាប់កូរជី -ក្បាលពោះវៀន និងអាចម៍កង្កែប១គីឡូ

-ខ្យង១គីឡូ-ខ្ទៅ១គីឡូ-សំបកក្តាម១គីឡូ-សំបកខ្នុរ សំបកល្ហុង-អាចម៍មាន់0,៥គីឡូ អាចម៍ប្រចៀវ 0,៥គីឡូ

-ទឹក-ស្ករត្នោតឬទឹកស្កររង្វ-ស្លឹកអង្កាញ់






## ១២.របៀបធ្វើជីទឹកប្រភេទទី១

១-យកក្បាលពោះវៀន និងអាចម៍កង្កែប ខ្យង ខ្ចៅ សំបកក្តាម សំបកខ្នុរ សំបកល្ហុង អាចម៍មាន់ និងប្រចៀវ ទៅដាក់ក្នុងពាងរួចច្របល់លាយចូលគ្នាឲ្យសព្វ ។

២-ចាក់ទឹកប្រមាណ១០០លីត្រចូលទៅក្នុងពាងរួចកូរឲ្យសព្វ។យកគំរបពាងគ្របពីលើឲ្យជិត ដើម្បីឲ្យទឹកជីឆាប់កាច់។

**<u>អ្នកជាំគួរដឹង</u>**

*ពាងទឹកជីតូច ឬធំអាស្រ័យទៅតាមបរិមាណជីដែលយើងចង់បាន។ រក្សាទុករយៈពេលពី២០ ទៅ២៥ថ្ងៃ ដើម្បីឲ្យទឹកជីកាច់ល្អទើបអាចយកទៅប្រើបាន ។*

## ១៣.របៀបធ្វើជីទឹកប្រភេទទី២

១-យកស្ករត្នោត ឬទឹកស្កររង្វ១ភាគ និងស្លឹកអង្កាញ់៣ភាគ ដាក់ត្រាំក្នុងពាង ឬធុងមួយដែលមានគំរបបិទជិត។

២-មួយថ្ងៃបង្កើបគ្របកូរម្តង ធ្វើដូច្នេះរយៈពេល១៥ថ្ងៃ។នៅពេលសង្កេតឃើញផ្សិតសៗអណ្តែតលើទឹក ហើយទឹកជីមានព័ណ៌ដូចទឹកតែ ទើបអាចយកទឹកជីនោះទៅប្រើបាន។

## ១៤.របៀបថែទាំទឹកជី និងរបៀបប្រើ

ពាងជីទាំងពីរប្រភេទ ត្រូវរក្សាទុកក្រោមម្លប់ឈើ ឬរោងប្រក់ដំបូល។ ត្រូវយកឈើ ឬឫស្សីទៅកូរក្នុងពាងជី ឲ្យមានខ្យល់ចេញចូល ដើម្បីឲ្យជីឆាប់កាច់។ មួយថ្ងៃបើកគំរបពាងកូរពីរដង(ព្រឹក និងល្ងាច)។ ពេលបើកគំរបពាងកូរ ត្រូវពាក់ម៉ាស់ដើម្បីការពារក្លិនជះមកលើ ។

**<u>អ្នកជាំគួរដឹង</u>**

*នៅពេលប្រើ ត្រូវដួសទឹកជីកុំឲ្យដោយកាកក្នុងបរិមាណទឹកជី ១លីត្រ លាយជាមួយទឹកធម្មតា១០លីត្រ។ក្នុងរយៈពេលពី២ទៅ៣ថ្ងៃត្រូវស្រោចម្តង។កុំស្រោចជីទឹកនៅពេលថ្ងៃត្រង់ ព្រោះអាចធ្វើឲ្យស្លឹកត្រកួនស្លោក។*

## ១៥.ការប្រមូលផលត្រកួន

ក្រោយពីដាំរយៈពេល១៥-២៥ថ្ងៃ យើងអាចដក ឬកាត់ត្រកួនបានហើយ ។

## ១៦.ការប្រមូលផលមានពីររបៀប



យើងអាចដកត្រកួនទាំងឫស ឬប្រើកូនកាំបិតដើម្បីកាត់វាក៏បាន។

<u>ការដកទាំងឬស</u> :

១-យើងប្រើដៃចាប់ដកត្រកួនទាំងឬសថ្នមៗរួចដាក់ក្នុងកញ្ជ្រែង។

២-បន្ទាប់មកលាងសំអាតដីដែលជាប់នៅនឹងឫសឲ្យបានស្អាត។

<u>អ្នកដាំគួរដឹង</u>

*ការប្រមូលផលដោយដកទាំងឫសធ្វើឲ្យយើងខាតបង់លុយច្រើន ។*

**ការកាត់ដើម**

យើងប្រើកូនកាំបិតដើម្បីកាត់ដើមត្រកួនដោយទុកគល់ពីដីប្រវែងពី២ទៅ៣សង់ទីម៉ែត្រដើម្បីឲ្យត្រកួនលាស់ត្រួយថ្មី។

**អ្នកគួរដឹង :**

*យើងអាចកាត់ត្រកួនបានចាប់ពី៨ទៅ១០ដងរហូតដល់ត្រកួនលែងដុះលូតលាស់ទៀត ។*

**ហេតុអ្វីការកាត់ត្រកួនត្រឹមគល់នាំឲ្យយើងចំណេញច្រើន?**

-ត្រកួនអាចដុះលូតលាស់បន្តទៀតដោយមិនបាច់ចំណាយលុយទិញពូជច្រើនដង។

-ឆាប់ទទួលបានផលជាងការដាំគ្រាប់ឡើងវិញ។

-មិនចំណាយកម្លាំងកាប់ដីនិងលើករងម្តងទៀតគឺយើងគ្រាន់តែជ្រំបំផុសដីក្នុងរងឡើងវិញប៉ុណ្ណោះ ។

## ១៧.ការថែទាំក្រោយពេលប្រមូលផល

ក្រោយពីកាត់ត្រកួនរួចយើងចាំបាច់ត្រូវជ្រំដី ដាក់ជីកំប៉ុស្ត ឬជីលាមកគោបន្ថែម និងបន្តស្រោចទឹក។

### ១៧.១.របៀបថែទាំត្រកួនក្រោយពីការកាត់



ក្រោយពីការកាត់ដើមលើកទី១ យើងអាចកាត់សារជាថ្មី

ក្នុងរយៈពេលពី១០ទៅ១៥ថ្ងៃម្តងជាបន្តបន្ទាប់។

<u>ការជ្រំដីនិងការដាក់ជី</u>

១-ក្រោយពីកាត់ត្រកួនរួច ត្រូវកាប់ ឬជ្រំដីនៅចន្លោះជួរត្រកួនក្នុងរង។

២-ដាក់ជីកំប៉ុស្ត ឬជីលាមកគោបន្ថែមចំនួនពី២ទៅ៣គីឡូក្រាម

លើផ្ទៃដី១ម៉ែត្របួនជ្រុង ។

៣-បន្តការស្រោចទឹកជីបំប៉នបន្ថែម២ថ្ងៃម្តង។

រួចបន្តការស្រោចទឹកធម្មតាមួយថ្ងៃ២ដង ព្រឹក និងល្ងាច ។

__**អ្នកដាំគួរដឹង**__ :

***ត្រូវដាក់ជីធម្មជាតិ(កំប៉ុស្តិ៍ ឬជីលាមកសត្វ)នៅក្រោយពេល***

***គាត់ប្រមូលផលក្លាម ឬមុនពេលកាត់១អាទិត្យដើម្បីឲ្យគល់ដំណាំឆាប់ចេញត្រួយថ្មី។***

## ១៨.ការទុកដាក់គ្រាប់ពូជត្រកួន

យើងអាចដាំត្រកួនដោយរក្សាទុកពូជខ្លួនឯងបានដោយមិនចាំបាច់ចំណាយលុយទិញគ្រាប់ពូជឡើយ ។

**ធ្វើដូចម្តេចទើបត្រកួនចេញផ្លែ?**



រយៈពេលរក្សាដើមត្រកួនដើម្បីយកគ្រាប់ទុកពូជត្រូវបន្តស្រោចទឹកនិង

ធ្វើស្មៅរហូតដល់វាចេញផ្កាទើបបន្ថយការស្រោចទឹកមួយថ្ងៃខានមួយថ្ងៃ។

__**កុំកាត់ដើមត្រកួន**__

១-រក្សាទុកដើមត្រកួនរហូតដល់រយៈពេល១ខែកន្លះទៅ២ខែរហូតដល់

គ្រាប់ត្រកួនទុំល្អហើយបេះផ្លែត្រកួនរួចយកមកហាលរយៈពេល២ថ្ងៃ ។

២-ប្រលេះយកគ្រាប់ចេញ រួចហាលថ្ងៃរយៈពេល៣០នាទី។

៣-អុំរោយយកកំទិចកំទីសំរាមចេញ។

៤-ច្រកគ្រាប់ចូលទៅក្នុងដបកែវ ចុកឆ្នុកឲ្យជិត(ឆ្នុកធ្វើអំពីស្មៅ ឬស្រកីដូងទុំ)ដើម្បីការពារសត្វខ្ចូតស៊ី។

__***ជៀសវាង***__ :

ទុកគ្រាប់ពូជត្រកួនយូរឆ្នាំទើបយកទៅដាំធ្វើឲ្យគ្រាប់ដុះមិនស្មើគ្នាល្អហើយដើមលូតលាស់យឺត។គ្រាប់ត្រកួនដែលដុះល្អ គឺទុកពី១ឆ្នាំកន្លះចុះក្រោម និងរក្សាទុកដាក់ឲ្យបានល្អ។

## ១៩.ម្ហូបម្ហាពីត្រកួន

យើងអាចយកត្រកួនទៅធ្វើម្ហូបបានច្រើនមុខ និងមានឱជារសឆ្ងាញ់ដោយមិនបាច់ប្រើប៊ីចេងឡើយ។

__**ឆាត្រកួនប្រេងខ្យង**__ :

ត្រកួន ប្រេងខ្យង ប្រេងឆា ខ្ទឹមស ម្ទេស ស្ករត្នោត អំបិល

១-លាងត្រកួនឲ្យស្អាត រួចកាត់វាជាកង់ៗ។

២-ដាក់ប្រេងក្នុងខ្ទះឆា ដាំឲ្យក្តៅ។ ចាក់ខ្ទឹមសចូលបំពងឲ្យឈ្ងុយ រួចចាក់ត្រកួននិងម្ទេសឆាចូលគ្នា។

៣-ដាក់ស្ករត្នោត អំបិល និងប្រេងខ្យងចូល រួចឆាពីរបីត្រឡប់ ហើយភ្លក់មើលតាមចំណង់ចំណូលចិត្តជាការស្រេច។

**ញាំត្រកួនសាច់គោ**:សាច់គោផុយល្អ ក្រូចឆ្មារ ទឹកត្រី ស្ករស អំបិល ទឹកត្រកួនជីរគ្រប់មុខខ្ទឹមស ខ្ទឹមក្រហម សណ្តែកដីលីង ម្ទេស។

១-ហាន់សាច់គោស្តើងៗ ប្រឡាក់អំបិលបន្តិច និងទឹកក្រូចឆ្មារ ទុកឲ្យឆ្អិនសាច់ទើបពូតយកទឹកចេញ។ បេះជីរគ្រប់មុខយកតែស្លឹក រួចលាងទឹកឲ្យស្អាត។

២-យកទឹកសាច់គោលាយជាមួយខ្ទឹមសចិញ្រ្ចាំ ទឹកត្រី ខ្ទឹមក្រហមហាន់ស្តើងៗ និងស្ករស រួចយកទៅដាំឲ្យពុះ ហើយភ្លក់មើលតាមការចូលចិត្ត ដើម្បីទុកធ្វើទឹកជ្រលក់។

៣-ពុះត្រកួនជាពីររួចមូរត្រលប់ទើបហាន់ជាសរសៃ។ យកត្រកួនច្របល់ជាមួយសាច់គោ ទឹកជ្រលក់ រោយជីរ និងសណ្តែកដីជាការស្រេច។

## ២០.ម្ហូបម្ហាផ្សេងៗទៀតពីត្រកួន

**គេអាចយកត្រកួនទៅ :**

-ឆាជាមួយសៀង ឬសាច់ជ្រូក -ឆាជាមួយប្រេង ជ្រលក់ទឹកអំបិលម្រេចក្រូចឆ្មារ -ស្លម្ជូរជាមួយត្រីបង់ម្អម។

-ស្លម្ជូរគ្រឿងជាមួយឆ្អឹងជំនីជ្រូក ឬសាច់គោ -ធ្វើបន្លែស៊ុបឆ្នាំងដី -ធ្វើភ្លាជាមួយសាច់គោ

-ធ្វើជ្រក់សំរាប់ញ៉ាំជាមួយសាច់អាំង -ធ្វើអន្លក់(ទឹកគ្រឿង ប្រហុក......)
-ធ្វើរបោយ(មី មីសួ គុយទាវ នំបញ្ចុក ពោះគោទឹកប្រហុក....)។

---

# ដំណាំឪឡឹក

## I-ស្ថានភាពទូទៅ

មានដំណាំយកផ្លែជាច្រើនប្រភេទដែលត្រូវស្ថិតក្នុងក្រុមបន្លែផងនិងជាដំណាំហូបផ្លែផង ដូចជាដំណាំឪឡឹក ជាដើមវាត្រូវបានគេបរិភោគផ្លែខ្ចីៗក្នុងតំបន់ប្រទេសក្រីក្រមួយចំនួនដែលមិនសំបូរបន្លែ ប៉ុន្តែដោយឡែកប្រទេសភាគច្រើន គេតែងតែបរិភោគផ្លែទុំជាបង្អែម ហើយមានប្រជាប្រិយភាពយ៉ាងខ្លាំងស្ទើរពេញពិភពលោក ។ ការនិយមចូលចិត្តបរិភោគដោយយោងទៅលើរសជាតិនិងសារធាតុផ្សេងៗសម្រាប់ទ្រទ្រង់រាងកាយដូចក្នុងតារាងអាហារូបត្ថម្ភ។
តារាងអាហារូបត្ថម្ភក្នុងទម្ងន់១០០ក្រាមបរិភោគបាន។

| ១០០ផ្លែទុំខ្ចាត | ទឹក ក្រាម | ថាមពល គីឡូ | ប្រូតេអ៊ីន ក្រាម | ប្រេង ក្រាម | វីតាមីនបេ មីលីក្រាម | វីតាមីនសេ មីលីក្រាម | កាលស្យូម មីលីក្រាម | ដែក មីលីក្រាម |
|---|---|---|---|---|---|---|---|---|
| បរិភោគបាន | ៩៥ | ៣,៣ | ០,២ | ០,២ | ០,០៤ | ១ | ១១ | ៧,៩ |

## II-បច្ចេកទេសដាំដុះ

### ១-ការជ្រើសរើសពូជ

នៅក្នុងការដាំដុះពូជជាកត្តាសំខាន់យ៉ាងចម្បងជាងគេ





ហើយមានជាច្រើនប្រភេទ មានពូជស្រាល កណ្តាល និងធ្ងន់ពូជទាំងនេះមិនអាចសមស្របក្នុងការដាំដុះគ្រប់តំបន់នោះទេឡើយមានពូជខ្លះសមស្របនឹងអាកាសធាតុត្រជាក់ ពូជខ្លះសមស្របនឹងអាកាសធាតុក្តៅ ហើយសុទ្ធសឹងជាពូជបង្កាត់ហាយព្រីតអែហ្វ១ មិនអាចយកគ្រាប់មកទុកពូជបន្ត បានឡើយ ព្រោះវាត្រូវបានផលិតដោយក្រុមហ៊ុនជាច្រើនលើពិភពលោក ។ ប៉ុន្តែក្នុងនោះពូជដែលផលិតដោយក្រុមហ៊ុននៅតំបន់អាស៊ីដូចជា ជប៉ុន តៃវ៉ាន់ ចិន ថៃ វៀតណាម ភាគច្រើនអាចដុះលូតលាស់ល្អក្នុងប្រទេសកម្ពុជាយើង ដោយឡែកពូជប្រពៃណីដែលធ្លាប់បានដាំដុះនៅក្នុងតំបន់ជុំវិញទន្លេសាបមុនសម័យសង្គ្រាមត្រូវផុតពូជទាំងស្រុង ជាពិសេសនៅតំបន់ព្រំប្រទល់ខេត្តកំពង់ធំ និងខេត្តសៀមរាប(កំពង់ឃ្លាំង ដំដែក កំពង់ចិន វាលក្រោម)។ វិធីសាស្ត្រក្នុងការជ្រើសរើសពូជមានៈ ត្រូវយល់ដឹងពីប្រភពថ្ងៃ ខែ ឆ្នាំផលិត ភាពសុទ្ធ អាយុកាលលូតលាស់ ជាពិសេសគឺពូជដែលបាន ណែនាំឲ្យប្រើប្រាស់។

**២-ការជ្រើសរើស និងការរៀបចំដី**

-ការជ្រើសរើសដីៈ ដើម្បីឲ្យការដាំដុះទទួលបានជោគជ័យល្អ គេត្រូវជ្រើសរើសដីដោយផ្អែកតាមលក្ខខណ្ឌដូចតទៅ ប្រភេទ ដីល្បប់ ដីល្បាយខ្សាច់ ដីក្រហមជើងភ្នំ ដីខ្មៅខ្ពង់រាប ដែលមានជីជាតិល្អ ស្រទាប់ដាំដុះជ្រៅ ជ្រាបទឹកបានរហ័ស ដែល មានប៉េហាស់ ពី ៥-៦,៨ ជាមធ្យម ជាពិសេសគឺមិនត្រូវយកដីដែលដាំដំណាំអម្បូរត្រសក់ ននោង ល្ពៅ ម្រះ ឃ្លោក ពីរដូវមុនមកដាំឪឡឹកឡើយ ហើយម្យ៉ាងទៀតវាមិនឆ្លើយតបទៅនឹងប្រភេទដីឥដ្ឋខ្លាំងឡើយ។

-ការរៀបចំដី ដំបូងត្រូវរាស់យកកាកសំណល់ផ្សេងៗនិងស្មៅចង្រៃចេញពីចំការឲ្យស្អាត បន្ទាប់មកភ្ជួរដីហាលឲ្យបានយូរថ្ងៃធ្វើឲ្យដីស្ងួត សម្លាប់ពពួកសត្វល្អិត និងកត្តាចង្រៃផ្សេងៗ ក្រោយមករាស់បំបែកដីឲ្យល្អិត និងកៀរឲ្យស្មើ។ ការភ្ជួរ និងរាស់ត្រូវធ្វើឡើងឲ្យបានចំនួន២-៣ដង ធ្វើឲ្យដីធូរ មានបន្ទុកខ្យល់គ្រប់គ្រាន់។ក្រោយពីភ្ជួរ និងរាស់រួចហើយ ត្រូវលើករងដោយនង្គ័ល ត្រាក់ទ័រ គោយន្ត ឬដោយចបឲ្យមានទទឹង ១,៥ម កម្ពស់រង ២៥-៣០ សង់ទីម៉ែត្រ បន្ទាប់មកយកជីធម្មជាតិ ឬ ជីកំប៉ុស្តមកដាក់ចំកណ្តាលរង ដោយប្រើ១៨-២០តោន និងជី ១៥.១៥.១៥ ចំនួន២០០គក្រ លើផ្ទៃដីមួយហិកតា ក្រោយមកពូនរងលុបដីឲ្យជិតកៀរឲ្យស្មើ ហើយគ្របចំបើង ឬគ្របកៅស៊ូ(កៅស៊ូគ្របដីដំណាំ)ឲ្យជិតទើបធ្វើការដាំដុះបាន ។

### ៣-ការដាំដុះ

គេអាចដាំដុះស្ទើរពេញមួយឆ្នាំប៉ុន្តែសំខាន់បំផុតគឺវាអាស្រ័យទៅតាមតំបន់។តំបន់វាលរាប និងមាត់ទន្លេបាសាក់ ទន្លេមេគង្គ និងទន្លេសាបគេអាចដាំពីខែតុលា វិច្ឆិកា ធ្នូ និងមករា អាចប្រមូលផលនៅខែធ្នូ ខែមករា និងកុម្ភៈ។ប៉ុន្តែចំពោះតំបន់ខ្ពង់រាបនិងតំបន់ភ្នំ គេអាចដាំពីខែ ឧសភា មិថុនា កក្កដា សីហា កញ្ញា និងខែតុលា ។ ការជ្រើសរើសរដូវកាលគឺសំដៅទៅលើលក្ខខណ្ឌអាកាសធាតុ វាអាចដុះលូតលាស់ចន្លោះពី ១៥អង្សា ទៅ ៣៥អង្សាសេ ។ វាត្រូវការទឹកភ្លៀងក្នុងដំណាក់កាលលូតលាស់រយៈពេល៣ខែ ចំនួន១២០ទៅ១៨០ មម ជាមធ្យមប្រចាំឆ្នាំ ១២០០មមនិងសំណើមបរិយាកាស ៥០%ជាមធ្យម ។ គេអាចដាំឪឡឹកតាមច្រើនវិធី អាស្រ័យទៅតាមតំបន់ដាំដុះគឺ ដាំដោយគ្រាប់ផ្ទាល់ និងដាំដោយកូន បណ្តុះ ។

**ក-ការដាំដោយគ្រាប់ផ្ទាល់**:មុនពេលដាំគេត្រូវយកគ្រាប់ពូជទៅហាលថ្ងៃរយៈពេលពីរម៉ោង បន្ទាប់មកយកគ្រាប់ពូជទៅត្រាំជាមួយសូលុយស្យុងកាប់តង់ ៥០% រយៈពេល២៥-៣០ នាទី ឬ គេអាចយក កាប់តង់២,៥-៣ក្រាម លាយជា មួយគ្រាប់ពូជទម្ងន់១គក្រ ទើបយកទៅដាំ ។ មុនដាំគេកាប់រណ្តៅនៅលើរងចន្លោះ១ម ជម្រៅរណ្តៅ៧-៨ សម បន្ទាប់មក យកថ្នាំប្រភេទ ហ្វូរ៉ាដង់ ចំនួន ១០គក្រ ក្នុង១ហត ដាក់បាតរណ្តៅ បន្ទាប់មកទើបដាំ១រណ្តៅ២-៣គ្រាប់ ហើយគ្របកំទេច ចំបើងស្ងួតពីលើទើបស្រោចទឹកតាមក្រោយមួយថ្ងៃ២លើក ។

**ខ.ការដាំដុះដោយកូនបណ្តុះ**: ក្រោយពីយកគ្រាប់ពូជទៅត្រាំ និងសូលុយស្យុងកាប់តង់រួចមកគេយកទៅបណ្តុះក្នុងកន្ទោងស្លឹកត្នោត ស្បោងកៅស៊ូដែលច្រក បំពេញដីដែលបានផ្សំជាមួយដីជាតិ៥ភាគ កំប៉ុស្ត៣ភាគ ដីខ្សាច់១ភាគ និង អង្កាម ១ភាគ លាយបញ្ចូលគ្នា ហើយដាក់គ្រាប់ ២ទៅ ៣គ្រាប់ក្នុងមួយកន្ទោង ហើយយកទៅតម្រៀបនៅកណ្តាលវាល គ្របចំបើង ស្ងួត បន្ទាប់មកស្រោចទឹកឲ្យជោកព្រឹក ល្ងាច ។ ៤៨ម៉ោងក្រោយមកយកចំបើងនោះចេញ បន្ទាប់មកទៀត រយៈពេល៤ថ្ងៃ គេស្រោចសូលុយស្យុងកាប់តង់,ស៊ីណែប ឬ បេណូមីល លាយកំរិត ១០គក្រ លាយទឹក១៥លីត្រ ទើបអាចយកទៅដាំបាន។ គេដាំមិនឲ្យលើស ៤-៥ថ្ងៃ ក្រោយបណ្តុះឡើយ គឺឪឡឹកមានស្លឹក២ធម្មតា ។ មួយហិកតា គេប្រើគ្រាប់ពូជ <u>២ទៅ ៣គក្រ</u> ។

### ៤.ការស្រោចស្រព

ដំណាំនេះត្រូវការទឹកជាមធ្យមចាប់ពីពេលវាដុះរហូតដល់វាចេញផ្កាឈ្មោល តែក្រោយពីឪឡឹកមានក្តឹប វាត្រូវការទឹកកាន់តែខ្លាំង រហូតដល់ពេលផ្លែចាប់ផ្តើមដាក់ជាតិស្ករ ។ គេអាចស្រោចរៀងរាល់ថ្ងៃ ឬ ២ថ្ងៃម្តងទៅតាមប្រភេទដី និង អាកាសធាតុ ។ ប៉ុន្តែវាអាចរស់ដោយសារទឹកភ្លៀង ឬសំណើមដីប្រមាណ ៧០ទៅ៨០% ។ ចំពោះការដាំនៅលើដីល្បប់ ល្បាយខ្សាច់តាមមាត់ទន្លេ គេដាំមិនប្រើប្រព័ន្ធស្រោចស្រពឡើយ ភាគច្រើនប្រើប្រាស់សំណើមក្នុងដីជាធម្មជាតិ និង សំណើមបរិយាកាសរហូតដល់ឪឡឹកជិតបានប្រមូលផលនោះទើបគេបន្ថយការស្រោចទឹក ។

### ៥.ការជ្រំជ្រោយដី

ប្រយោជន៍នៃការជ្រំជ្រោយដី គឺធ្វើឲ្យដីធូរ បន្ថយការដុះស្មៅ សំរួលដល់បន្ទុកខ្យល់ចេញចូលបានល្អ ធ្វើឲ្យដីរក្សា សំណើមបានយូរបង្កឲ្យសារធាតុរលួយបានលឿន ឬសឪឡឹកលូតលាស់ល្អស្រូបកជីជាតិបានរហ័សទៅចិញ្ចឹមសរីរាង្គ ។ របៀបជ្រំជ្រោយដី គឺគេជ្រំឲ្យផុសដីពេញផ្ទៃរង ហើយពូនលុបគល់ឪឡឹកឲ្យជិតរយៈពេល ១៥-១៨ថ្ងៃក្រោយដាំ ។ ក្រោយពីជ្រំហើយត្រូវកាត់ស្លឹក និងខ្នែងដែលដុះពីថ្នាំងទី១-២-៣ចេញ បន្ទាប់មកកប់ទងឪឡឹកទៅក្នុងដី ដើម្បីឲ្យឬសថ្មី ដុះចេញពីថ្នាំងទាំងនោះ ជំនួយដល់ការលូតលាស់បន្ថែមទៀត ។

**៦.ការដាក់ជីបំប៉ន**

ឪឡឹកក៏ដូចជាដំណាំឯទៀតដែរ វាទាមទារឲ្យមានការផ្តល់ជីឲ្យបានគ្រប់គ្រាន់ទៅតាមតម្រូវការរបស់វាក្នុងវគ្គនីមួយៗដូចនេះគេចែកចេញការដាក់បន្ថែមជីចំនួន៣លើកដូចតទៅ៖

-ការស្រោចបំប៉នលើកទី១៖
នៅក្នុងវគ្គនេះឪឡឹកត្រូវការសារធាតុអាសូតច្រើនជាងគេក្នុងកំឡុង១០ថ្ងៃក្រោយដាំ
ដូចនេះត្រូវយកជីអ៊ុយរ៉េចំនួន១៥ក្រាម លាយទឹក២០លីត្រ ស្រោចចំគុម្ព ហើយស្រោចទឹកលាងតាមក្រោយក្នុង១ហាត អាចប្រើជីអស់ចំនួន៣៥ទៅ៤០គីឡូក្រាម។

-ការដាក់ជីបំប៉នលើកទី២៖នៅក្នុងវគ្គនេះវាត្រូវការសារធាតុទាំងបីមុខគឺ អាសូត ផូស្វ័រ និងប៉ូតាស្យូម ដូចនេះ គេត្រូវយកជី១៥.១៥.១៥ ចំនួន២៥ទៅ ៣០ក្រាម ក្រោយពីដាំបានរយៈពេល២០ទៅ ២៥ថ្ងៃ ដោយដាក់ជុំវិញគល់ហើយ កាប់ដីលប់ឲ្យជិតនិងស្រោចទឹកឲ្យជោកក្នុង១ហ.ត អាចប្រើ២០០ទៅ២៥០គីឡូក្រាម។

-ការដាក់បំប៉នលើកទី៣៖ នៅក្នុងវគ្គចុងក្រោយនេះ គេតែងតែដាក់ជី២ប្រភេទរួមគ្នា គឺជីអ៊ុយរ៉េ និងជីប៉ូតាស្យូម ដើម្បីឲ្យឪឡឹកទុំក្រហមហើយមានរសជាតិផ្អែម។ ចំនួនជីអ៊ុយរ៉េពី៤៥ទៅ៥០គក្រ ជីប៉ូតាស្យូម៥០%ចំនួន៤៥-៥០គក្រ លាយបញ្ចូលគ្នា ហើយដាក់លើផ្ទៃដី ១ហ.ត ក្រោយពីឪឡឹកផ្លែធំ(តាមប្រភេទពូជ) មុនប្រមូលផលពី១៥-២៥ថ្ងៃ ។

**III-អំពីជម្ងឺ និងវិធានការការពារ**

ឪឡឹកតែងទទួលរងនូវជម្ងឺជាច្រើនប្រភេទដែលបង្កឡើងដោយមេរោគ៣ក្រុមធំៗ គឺបង្កដោយវីរុស ផ្សិត និងបាក់តេរី.........។

**១.<u>ក្រុមជម្ងឺបង្កដោយវីរុស</u>៖** វីរុសដែលតែងតែកើតលើដំណាំឪឡឹកមានពីរប្រភេទដែលសំខាន់គឺ:

**-<u>វីរុសបង្កឲ្យរួញត្រួយ</u>៖**គេតែងសង្កេតឃើញត្រួយខ្ចីៗរបស់ឪឡឹករួញហើយងើបទងឡើងលើ ស្លឹកដែលលូតលាស់ ចេញមករួញក្រញាញ់ ជាពិសេសនៅក្នុងវគ្គកំពុងចេញផ្កា និងផ្លែខ្ចីៗ ធ្វើឲ្យថយចុះនូវការបន្តពូជ ផ្លែមិនរីកធំធាត់បាន ហើយផ្លែទុំគ្មានរសជាតិ ផ្លែបាត់បង់ទិន្នផលយ៉ាងច្រើន.......។

**-<u>វីរុសបង្កឲ្យរួញស្លឹក</u>៖** គេសង្កេតឃើញស្លឹកឪឡឹកប្រែព័ណ៌ពីបៃតងទៅបៃតងចាស់ហើយក្រាស់ បន្ទាប់មករួញ ស្លឹកក្តោបចុះមកក្រោម នៅក្នុងវគ្គចេញផ្លែធ្វើឲ្យផ្លែប្រែប្រួលទម្រង់ទៅជាក្រិនលែងរីកលូតលាស់ សម្បករឹងពន្យាពេលទុំ

ហើយគ្មានរសជាតិ បាត់បង់ទិន្នផលយ៉ាងច្រើនកាលណារងការបំផ្លាញដោយជម្ងឺនេះ ។ ជម្ងឺទាំងពីរប្រភេទគឺចៃខ្មៅ និងចៃបៃតង។ ដើម្បីទប់ទល់ទៅនឹងជម្ងឺនេះគេប្រើប្រាស់ពូជធន់ទ្រាំ ត្រួតពិនិត្យវត្តមានចៃឲ្យបានត្រឹមត្រូវ និងទាន់ពេលវេលា ហើយដកដើមដែលកើតជម្ងឺយកទៅដុតចោល និងត្រូវប្តូរដីដាំដុះ ។

**២.<u>ក្រុមជម្ងឺបង្កឡើងដោយមេរោគផ្សិត</u>**:
មានជម្ងឺជាច្រើនប្រភេទដែលបំផ្លាញឪឡឹកចាប់ពីវគ្គដុះពន្លករហូតដល់ពេលប្រមូលផលក្នុងនោះមាន:

**-ផ្សិតបង្កដោយរលួយកូន**:បង្កដោយមេរោគបីប្រភេទដែលតែងតែធ្វើឲ្យរលួយកូនឪឡឹកក្នុងអំឡុងអាយុកាលពី៥ទៅ ១០ថ្ងៃ ។

-

**ជម្ងឺបង្កឲ្យពុកឫស**:គេសង្កេតឃើញកើតជាញឹកញាប់នៅរដូវក្តៅសើមនៅក្នុងវគ្គកំពុងបន្តពូជធ្វើឲ្យពុករលួយដើមហើយស្រពោនលែងលូតលាស់បន្ត។

-

**ផ្សិតបង្កដោយមានប្រជ្រុយស្លឹក**:ជាពិសេសនៅក្នុងវគ្គជិតប្រមូលផលធ្វើឲ្យលេចឡើងនូវស្នាមអុចៗដូចប្រជ្រុយព័ណ៌ត្នោតភ្លីពេញផ្ទៃស្លឹកបន្ទាប់មកនោះនឹងស្ងួតធ្វើឲ្យផ្លែឪឡឹកទុំមិនតាមអាយុកាលរបស់វាហើយកើតឡើងគ្រប់រដូវ ។

-

**ជម្ងឺខ្មៅស្លឹកនិងដើម**:វាបង្កឡើងដោយមេរោគហើយច្រើនតែកើតនៅរដូវវស្សាធ្វើឲ្យស្លឹកលេចចេញចំណុចខ្មៅដូចធ្យូងផ្ទាំងៗធំៗព្រមទាំងដើមដុះផ្សិតខ្មៅធ្វើឲ្យឪឡឹកងាប់ពាក់កណ្តាលដើម ។

**-<u>វិធានការការពារនិងកំចាត់</u>**:មុននឹងដាំ យកគ្រាប់ពូជត្រាំទឹកក្តៅកំដៅ៥០°C រយៈពេល១៥ទៅ ២០នាទី លាងសំអាតគ្រាប់ឲ្យស្អាត និងឧបករណ៍បណ្តុះត្រូវសម្លាប់មេរោគជាមុន ក្រោយពីដុះបានរយៈពេល៥ទៅ៧ថ្ងៃ យកថ្នាំសម្លាប់ផ្សិត ដូចជាស៊ីណែប,កាប់តង់ទម្ងន់២០ក្រាមលាយទឹក១៥លីត្របាញ់ឲ្យជោកទៅលើកូនឪឡឹកខ្ចីៗ ត្រូវប្តូរដីក្នុងការដាំដុះ និងជ្រើសរើសរដូវកាលឲ្យបានសមស្រប ពេលលេចចេញនូវសញ្ញាត្រូវបន្ថយការស្រោចទឹក និងបំប៉នដីដែលមានសារធាតុអាសូតច្រើន ។

**៣.<u>ក្រុមជម្ងឺបង្កឡើងដោយបាក់តេរី</u>**:បាក់តេរីជាជម្ងឺមួយដែលឆ្លង និងរីករាលដាលយ៉ាងខ្លាំងព្រមទាំងធ្វើឲ្យដំណាំខូចខាតជាទម្ងន់។ លើដំណាំឪឡឹកគេសង្កេតឃើញមានបាក់តេរី២ប្រភេទដូចតទៅ:

**-បាក់តេរីធ្វើឲ្យស្រពោន**:មេរោគនេះភាគច្រើនរស់នៅក្នុងដី និងទឹក វាជ្រៀតចូលទៅដើមដំណាំជាបណ្តើរៗចាប់តាំងពីដំណាំដុះលូតលាស់ដំបូង ប៉ុន្តែអាចធ្វើឲ្យឪឡឹកស្រពោនហើយក្រៀមស្វិតមិនអាចលូតលាស់បន្តទៀតបាននៅក្នុងវគ្គពង្រីកផ្លែ ជាពិសេសនៅតំបន់ខ្ពង់រាប និងភ្នំ ។

**-បាក់តេរីបង្កឲ្យខ្លោចស្លឹក**:ជម្ងឺនេះតែងតែកើតទៅលើស្លឹក ដើម បង្កើតបានជាចំណុចខ្លោចៗតូចៗដូចប្រជ្រុយហើយស្ងួតធ្វើឲ្យស្លឹកជ្រុះ ឪឡឹកមិនអាចលូតលាស់បានជាពិសេសនៅដើមរដូវវស្សាអាកាសធាតុក្តៅសើម ។ដើម្បីទប់ទល់នឹងជម្ងឺទាំងនេះ គេត្រូវបាញ់ថ្នាំសម្លាប់សត្វល្អិតស្លាបរឹង ដែលស៊ីពីដើម១ទៅដើមមួយ

ប្រើប្រាស់ពូជធន់ ផ្លាស់ប្តូរដី ព្រមទាំងគ្រាប់ពូជដែលគ្មានជាប់មកជាមួយនូវមេរោគ។ ចំពោះជម្ងឺបាក់តេរីស្អុត គេប្រើថ្នាំសម្លាប់ផ្សិតដែលផ្សំឡើង ដោយទង់ដែងអុកស៊ីត ពេលលេចចេញសញ្ញាដំបូង ។

## IV-**អំពីសត្វល្អិតចង្រៃ និងការការពារ**

មានសត្វល្អិតចង្រៃជាច្រើនប្រភេទដែលបំផ្លាញដំណាំក្នុងនោះមានសត្វល្អិតជាភ្នាក់ងារបង្ករោគ និងសត្វល្អិតបំផ្លាញផ្ទាល់។

**១.សត្វល្អិតជាភ្នាក់ងារបង្ករោគ:** មានសត្វល្អិតជាច្រើនប្រភេទដែលបំផ្លាញដំណាំ ហើយបណ្តាលឲ្យកើតជម្ងឺជាពិសេសជម្ងឺវីរុសដូចជា:

-ចៃបៃតង -ចៃខ្មៅ -មមាចជញ្ជក់ស្លឹក -រុយស

ការបំផ្លាញរបស់សត្វល្អិតទាំងនេះភាគច្រើនកកេរ និងកាត់បំផ្លាញទាំងស្លឹក ផ្កា ផ្លែ ដើម ក្នុងនោះ.

-អណ្តើកមាសព័ណ៌លឿង វាស៊ីស្លឹកកូទីឡេដុង ត្រួយខ្ចីៗ ផ្កានិងក្តិបខ្ចីៗ បន្ថយការលូតលាស់ ព្រមទាំងរំខានដល់ការបន្តពូជ។

-ដង្កូវកាត់ដើម: ដង្កូវប្រភេទនេះច្រើនជ្រកលាក់ខ្លួននៅក្នុងដីពេលថ្ងៃ ហើយកាត់បំផ្លាញដើមដំណាំខ្ចីៗនៅពេលយប់ ។

-ដង្កូវហ្វូងស៊ីស្លឹក និងផ្លែ វាស៊ីបំផ្លាញស្លឹក ផ្កា ផ្លែខ្ចី ហើយមានលក្ខណៈជាហ្វូងៗ ។

-ដង្កូវមូរស្លឹក ដង្កូវប្រភេទនេះចូលចិត្តជ្រក និងស៊ីត្រួយខ្ចីៗគ្រប់ដំណាក់កាលលូតលាស់ ប៉ុន្តែវាអាចស៊ីផ្កាធ្វើឲ្យរំខានដល់ការបន្តពូជផងដែរ ។

**២.វិធានការការពារ និងកំចាត់:**ដើម្បីទប់ទល់ទៅនឹងកត្តាចង្រៃនេះគេត្រូវអនុវត្តវិធានការយ៉ាងច្រើនដូចជា: ជ្រើសរើសរដូវ ផ្លាស់ប្តូរមុខដំណាំ ជ្រើសរើសពូជធន់ទ្រាំ រៀបចំដីឲ្យបានត្រឹមត្រូវ សំអាតស្មៅក្នុងចំការ ជាពិសេសក្នុងការគ្រប់គ្រងវត្តមានសត្វល្អិតជាប្រចាំមុនពេលវាពេញវ័យ ហើយអាចអនុវត្តវិធានការគីមីដោយប្រើប្រាស់ថ្នាំពុលកសិកម្មឲ្យបានសមស្រប ។

## V-**ការប្រមូលផល**

ដោយយោលទៅលើឪឡឹកជាប្រភេទដំណាំប្រមូលយកផ្លែទុំពេញលក្ខណៈនៅនឹងដើម ដូចនេះគេត្រូវសំគាល់ទៅ លើដៃទាំងពីរអមទងផ្លែ កាលណាវាស្ងួត៧០%ពីខាងចុងទៅគល់ ហើយសំបកនៃផ្លែមានក្រាមម្សៅក្រាស់នោះ ជាអាយុកាលដែលអាចប្រមូលផលបានដោយប្រើកាំបិត ឬកន្ត្រៃកាត់ផ្តាច់ទងហើយដឹកជញ្ជូនយកទៅរក្សាទុកកន្លែង ត្រជាក់ មិនត្រូវដាក់ឲ្យត្រូវកំដៅថ្ងៃឡើយធ្វើឲ្យបាត់បងសោភ័ណភាព និងគុណភាព ។ ប្រភេទពូជស្រាលមានអាយុពី ៥៥-៦០ថ្ងៃ ពូជកណ្តាល៦៥-៧៥ថ្ងៃ និងពូជធ្ងន់ពី៨០-៩០ថ្ងៃក្រោយដាំ ហើយទិន្នផលជាមធ្យមពី<u>១៥-១៧តោន ក្នុង១ហិកតា</u>។

# ដំណាំត្រប់

## I.ស្ថានភាពទូទៅ

ត្រប់មានច្រើនប្រភេទដូចជាត្រប់ពុតញង,ត្រប់ស្រួយ ត្រប់ខារ ឬត្រប់ពងមាន់។

ត្រប់ក្រាំងរមាស ឬ ត្រប់សណ្តាយដែលមានផ្លែសំប៉ែត ឬ មូលតែពណ៌ប្រផេះ ឬបៃតង។ជាទូទៅគេពិនិត្យឃើញមានចំនួន២២ប្រភេទនៃក្រុមសូឡានូមនៅក្នុប្រទេសឥណ្ឌា។

នៅប្រទេសកម្ពុជាយើងត្រប់ជាប្រភេទបន្លែមួយយ៉ាងសាមញ្ញដែលប្រជាជនគ្រប់គ្នាតែងតែបរិភោគជាបន្លែក្នុងជីវភាពប្រចាំថ្ងៃ។គេដាំដុះវាជាលក្ខណៈចំការធំៗតាមបណ្តោយទន្លេមេគង្គនិងតំបន់ផ្សេងៗទៀតជាច្រើនតែដាំជាលក្ខណៈសួនបន្លែចំរុះ។



## II.លក្ខខណ្ឌដីនិងអាកាសធាតុ

### ១.លក្ខខណ្ឌអាកាសធាតុ

ដំណាំត្រប់គ្រប់ប្រភេទឆាប់ទទួលរងនូវអំពើប្រែប្រួលពីអាកាសធាតុជាពិសេសនៅពេលសីតុណ្ហភាពត្រជាក់សំណើមបរិយាកាសខ្ពស់។ ប្រសិនបើសីតុណ្ហភាពមធ្យមប្រចាំថ្ងៃចន្លោះពី១៨-២៥អង្សាសេធ្វើឲ្យការដុះលូតលាស់និងទិន្នផលខ្ពស់ជាទីបំផុតគឺដុះលូតលាស់លឿនផ្កាចេញស្រុះគ្នាល្អកំរិតបន្តពូជនិងការធំធាត់របស់ផ្លែបានល្អ។នៅពេលសីតុណ្ហភាពឡើងខ្ពស់ពី៣០-៣៣អង្សាសេ និងមានខ្យល់បក់ខ្លាំងក្នុងអំឡុងពេលត្រប់ចេញផ្កាវាធ្វើឲ្យមានឥទ្ធិពលអាក្រក់ដល់ផ្ការីក ហើយលទ្ធផលទិន្នន័យថយចុះក៏កាន់តែខ្លាំង។គ្រាប់ពូជដុះពន្លកបានល្អ គឺជាមធ្យម២៥អង្សាសេ។

### ២.អំពីលក្ខខណ្ឌដី

ត្រប់គឺជាប្រភេទដំណាំមួយដែលអាចដុះលូតលាស់បានលើផ្ទៃដីស្ទើរគ្រប់ប្រភេទ។ប៉ុន្តែដីដែលសមស្របសម្រាប់ដំណាំនេះគឺដីឥដ្ឋល្បាយ និងដីល្បាយខ្សាច់ ធ្វើឲ្យត្រប់ទទួលបានទិន្នផលខ្ពស់។ប៉ុន្តែដីសម្រាប់ដាំត្រប់គួរតែស្រទាប់ដាំដុះជ្រៅ និងប៉េហាស់ចាប់ពី ៥,៥-៦,០ទើបទទួលបានល្អប្រសើរជាងដីដែលមានស្រទាប់ដាំដុះរាក់ប៉េហាស់ទាបជាង៥ ឬខ្ពស់ជាង៨ វាតែងតែធ្វើឲ្យត្រប់ជួបប្រទះនូវបញ្ហាជម្ងឺកង្វះសារធាតុចិញ្ចឹមច្រើនលើផ្លែ ។

III.**បច្ចេកទេសដាំដុះ**

***១.ការជ្រើសរើសពូជនិងសំរិតសំរាំងកូន***

-<u>ការជ្រើសរើសពូជ</u>៖ដំណាំត្រប់ក៏ដូចជាដំណាំឯទៀតដែរ ការជ្រើសរើសពូជមានសារៈសំខាន់បំផុតគឺសំដៅទៅការលូតលាស់និងឲ្យផលខ្ពស់។ពូជត្រូវដឹងប្រភពត្រឹមត្រូវ ប្រភេទពូជពាណិជ្ជកម្មមិនអាចទុកដាំបានឡើយ ។ ពូជក្នុងស្រុកមានអាយុកាលលូតលាស់សមស្របនឹងតំបន់ដាំដុះ ព្រមទាំងពេញនិយមប្រើប្រាស់អាចទុកដាំបន្តទៀតបាន។ គ្រាប់ពូជមានសុខភាពល្អ ភាពសុទ្ធ ការកំណត់ប្រើជាក់លាក់។

-<u>ការសាបកូននិងថែទាំកូនត្រប់</u>៖ គ្រាប់ត្រប់តូចល្អិត សំប៉ែត សំបករឹងហើយក្រាស់ ជាទូទៅចំនួន ២៥០គ្រាប់ឲ្យទម្ងន់១ក្រាម។ដើម្បីដាំលើផ្ទៃដី១ហ.ត គេត្រូវប្រើគ្រាប់ពូជចំនួន <u>**៣៧៥ ទៅ ៥០០ក្រាម**</u> ។ មុននឹងសាបគ្រាប់ពូជត្រូវយកមកសំអាតជាមុន បន្ទាប់មកយកទៅដាក់ហាលថ្ងៃរយៈពេល១ទៅ ២ម៉ោង ក្រោយមកទៀតយកទៅត្រាំទឹកក្តៅ ឧណ្ហៗរយៈពេល១៥-២០នាទីទើបត្រាំទឹកត្រជាក់ធម្មតាមួយយប់ ក្រោយមកយកទៅផ្អាប់ពីរយប់ នៅពេលគ្រាប់ត្រប់ដុះពន្លកសៗ ដំបូងអាចយកទៅសាប ឬដាក់ក្នុងកន្ទោង ក៏បាន។ របៀបសាប ឬបណ្តុះត្រប់មានច្រើនវិធីដូចខាងក្រោមនេះ៖

-<u>វិធីសាបនឹងថ្នាលធម្មតា</u>៖ ដំបូងត្រូវរកទីតាំងថ្នាលសាបគឺស្រឡះ ដីទួល ស្រស់ទឹក មានជីជាតិល្អ បន្ទាប់មកត្រូវកាប់ហាលដីឲ្យស្ងួត ទើបលើករងឲ្យបានត្រឹមត្រូវ ដីលើរងគឺឲ្យម៉ដ្ឋល្មមកៀរឲ្យស្មើរ(គួរធ្វើដំបូលប្រក់ពេលមេឃភ្លៀង)ទើបយកជីប្រភេទស៊ុបពែផូស្វាតមកបាចពីលើចំនួន<u>**១៥០ក្រាមសម្រាប់ផ្ទៃថ្នាល១០ម²ឬជី១៥.១៥.១៥ ចំនួន២០០ក្រាម**</u> បន្ទាប់មករាស់លុបជីទាំងនោះឲ្យកប់ជ្រៅទៅក្នុងដី។ ការសាបគ្រាប់ពូជត្រូវធ្វើឡើងជាបន្ទាន់ ដោយសាបឲ្យរង្វើលល្មម ក្រោយសាបហើយត្រូវរោយកំទេចចំបើង ចិញ្ច្រាំខ្លីៗពីលើតាមក្រោយ ដើម្បីការពារសំណើមដី បន្ទាប់មកស្រោចទឹកឲ្យជោក ហើយស្រោចសូលូស្យុងថ្នាំផ្សិតដូចជា <u>**ម៉ង់កូសែប**</u> ការពារជម្ងឺរលួយកូននៅពេលវាដុះថ្មីៗ។ ការស្រោចទឹក ដកស្មៅ និងជីបំប៉ន ត្រូវធ្វើឡើងជាប្រចាំ ដើម្បីឲ្យកូនដំណាំលូតលាស់ល្អ ក្រោយពីសាបរយៈពេល៣ ទៅ ៤ អាទិត្យអាចដកយកទៅដាំបាន ។

-<u>ការសាបនឹងថ្នាលដីខ្សាច់</u>៖ដំបូងត្រូវធ្វើឡាំងឬកេសដែលមាន ទទឹង០,៥ម បណ្តោយ១ម ជម្រៅ ៥សម បាតកេសត្រូវមានរន្ធតូចៗ ។ យកដីខ្សាច់ម៉ដ្ឋមកដុតសម្លាប់មេរោគជាមុនហើយទុកឲ្យត្រជាក់ទើបចាក់ចូលក្នុងកេសឲ្យពេញ ស្រោចទឹកឲ្យជោគ បន្ទាប់មកយកគ្រាប់ដែលដុះពន្លកសៗ ទៅសាបតាមចង្អូរជម្រៅ១សម ចន្លោះជួរ៥សម ក្រោយសាបហើយត្រូវលុបដីខ្សាច់នោះពីលើឲ្យជិត គ្របចំបើងស្ងួតពីលើហើយស្រោចទឹកឲ្យជោគ ព្រឹក ល្ងាចរយៈពេល២ទៅ៣ថ្ងៃ អាចបកចំបើងនោះចេញ គឺពេលត្រប់ដុះទូដីខ្សាច់ចេញ មក។

ក្រោយពីវាដុះមានសន្លឹកកំណើតពីដំបូងមានអាយុ៧ទៅ១០ថ្ងៃ អាចដកកូនពីកេសដីខ្សាច់ទៅស្ទូង លើថ្នាល ឬកន្ទោងដែលបានបំពេញដោយដីមានជីជាតិពិសេសដីជីកំប៉ុស្ត និងអង្កាម ។

ការថែទាំស្រោចទឹក ស្រោចជី អាចធ្វើឡើងដូចគ្នានឹងការសាបថ្នាលធម្មតាដែរ តែការសាបរបៀបនេះ ប្រើគ្រាប់ពូជចំនួនតិចអាចដាំបានផ្ទៃដីធំ ហើយកូនត្រប់ឆាប់បានយកទៅដាំគឺរយៈពេលតែ៣អាទិត្យប៉ុណ្ណោះ។

## *២. រដូវកាលដាំដុះ*

ត្រប់ជាប្រភេទដំណាំមួយដែលលូតលាស់ពេញមួយឆ្នាំ ដោយមិនប្រកាន់រដូវ ក៏ប៉ុន្តែនៅពេល សីតុណ្ហភាពឡើងខ្ពស់ធ្វើឲ្យត្រប់បន្ថយការចេញផ្កា ឬ ពេលសំណើមដីមិនគ្រប់គ្រាន់ធ្វើឲ្យត្រប់ផ្លែមិនបានវែង ហើយមានរសជាតិល្វីងខារ នៅប្រទេសកម្ពុជាយើងគេបែងចែករដូវដាំដុះជាពីរគឺរដូវប្រាំងនិងរដូវវស្សា។ នៅតំបន់ទំនាបទន្លេមេគង្គនិងជុំវិញទន្លេសាបការដាំដុះចាប់ផ្តើមពីរដូវទឹកសម្រកនៅខែតុលា វិច្ឆិកា ដល់ខែកក្កដា និងសីហា នៅតំបន់ខ្ពង់រាប និងភ្នំ គឺពីខែឧសភា ដល់ខែវិច្ឆិកា ដែលភាគច្រើនស្រោចស្រពដោយទឹកភ្លៀង ។

## *៣.ការរៀបចំដី*

ការរៀបចំដីមានសារៈសំខាន់បំផុតសម្រាប់ការដាំនិងដុះលូតលាស់។ ដំបូងត្រូវរាស់ប្រមូលនូវស្មៅ កាកសំណល់ដំណាំចាស់ ដុត ឬ យកចេញពីចំការ បន្ទាប់មកភ្ជួរហាលដីរយៈ ពេល៥ ទៅ ៧ ថ្ងៃឲ្យស្មៅងាប់ និងផ្តាច់ជីវិតពពួកសត្វល្អិតចង្រៃផ្សេងៗនៅក្នុងដី ក្រោយមកទើបរាស់បំបែកដីឲ្យម៉ដ្ឋ និងគៀរឲ្យស្មើ។ ដើម្បីលើករងដាំបានត្រូវភ្ជួររាស់ដីឲ្យបាន៣ ទៅ ៤ លើក ។ ការដាំតាមរបៀបកសិករគេមិនលើករងឡើយ តែដើម្បីឲ្យងាយស្រួលស្រោចគេលើករង ។ ការលើករងមានសារៈសំខាន់បំផុត ដូចជានៅរដូវវស្សាការលើករងឲ្យមានកំពស់ខ្ពស់ធ្វើឲ្យទឹកហូរចេញពីចំការបានរហ័ស។ នៅរដូវប្រាំងករណីរងខ្ពស់ងាយបញ្ចូលទឹក។ រង ឬថ្នាលសម្រាប់ដាំត្រប់គឺមានទទឹង១ ម កំពស់ ២០ ទៅ ២៥សម បណ្តោយតាមលទ្ធភាព ឬ សភាពរបស់ដី ។

## *៤.របៀបដាំដុះ*

បន្ទាប់ពីលើករងហើយត្រូវកាប់ជារណ្តៅតាមបណ្តោយរង ឬថ្នាលដាំមួយជួរគឺចន្លោះ ១ ទៅ១,២ម ចន្លោះគុម្ព៧០ ទៅ ៨០សម មួយគុម្ពមួយដើម ។ ជម្រៅរណ្តៅដែលកាប់គឺ ៨ ទៅ ១០ សម ក្នុងករណីកូន ត្រប់សាបលើថ្នាលផ្ទាល់ គេត្រូវស្រោចទឹកកូនត្រប់ឲ្យជោគរយៈពេល ២០ទៅ ៣០នាទី មុនដក ដើម្បីបន្ធូរនូវ ការដាច់ឫស ។ កូនត្រប់ត្រូវដកពីពេលព្រឹក បន្ទាប់មកយកវាទៅដាក់ក្នុងឧបករណ៍ដូចជាកញ្ជើ ល្អី កញ្ចេ។ល។ ហើយស្រោចទឹកឲ្យជោគរក្សាទុកនៅក្រោមម្លប់ ធ្វើឲ្យកូនត្រប់មានសភាពរឹងមាំធន់កំដៅថ្ងៃ ក្រោយមកទើបយកទៅដាំនៅពេលរសៀលចាប់ពីម៉ោង២រហូតដល់ពេលល្ងាចត្រជាក់ ក្រោយពីដាំភ្លាមត្រូវ ស្រោចទឹកឲ្យជោគតាមរណ្តៅនីមួយៗ ។

 

*៥.ការស្រោចស្រព*

ទឹកជាកត្តាសំខាន់សម្រាប់បំលែងសារធាតុចិញ្ចឹម គឺធ្វើឲ្យជីជាតិទាំងឡាយនៅក្នុងដីរលាយ ហើយអាចឲ្យដំណាំស្រូបយកបានទៅចិញ្ចឹមសរីរាង្គ ។ ត្រប់ជាប្រភេទដំណាំមួយដែលត្រូវការទឹកជាប្រចាំ ដើម្បីរក្សាសំណើមដី ដូចនេះចាប់ពីពេលដាំភ្លាមត្រូវតែស្រោចទឹកជាបន្ទាន់ ហើយបន្តស្រោចជាធម្មតាមួយថ្ងៃ ១ ទៅ ២លើក ព្រឹក ល្ងាច ប៉ុន្តែនៅពេលត្រប់ចាប់ផ្តើមចេញផ្កា រហូតដល់ពេលប្រមូលផលវាត្រូវការទឹកច្រើនជាង ពេលដាំ ។ ក្នុងដំណាក់កាលនេះគេអាចបញ្ចូលដោយម៉ាស៊ីនទៅតាមចន្លោះរងក៏បាន ហើយបាញ់ឲ្យជោគ ក៏បាន ធ្វើយ៉ាងណាឲ្យដីមានសំណើមកាន់តែខ្លាំងក្នុងដំណាក់កាលនេះ ជាពិសេសនៅរដូវប្រាំង ។

*៦.ការប្រើប្រាស់ជី*

ត្រប់ត្រូវការសារធាតុចិញ្ចឹមគ្រប់មុខ គឺវាត្រូវការដីដែលមានជីជាតិច្រើនដែលជាសមាសធាតុសម្រាប់ផ្តល់ដល់ការលូតលាស់និងមានទិន្នផលខ្ពស់។ ជីធម្មជាតិដូចជាកំប៉ុស្តផ្សំលាមកសត្វគ្រប់ប្រភេទ ជីស្រស់ ឬជីបៃតងសុទ្ធសឹងជាសមាសធាតុដែលបណ្តាលឲ្យលូតលាស់លឿននិងទិន្នផលខ្ពស់។ ជីអាចម៍មាន់គេប្រើកំរិតពី**<u>៨ ទៅ ១០តោន/ហ.ត</u>** ជីលាមកគោ ក្របី ចំនួនពី **<u>១៥ទៅ ២០តោន/ហ.ត</u>** ជាពិសេសគឺដាក់នៅពេលដាំ ដែលហៅថាជីទ្រាប់បាត។ដំណាំនេះត្រូវការសារធាតុសំខាន់ៗដូចជា អាសូត,ផូស្វ័រត,ប៉ូតាស្យូម និងប័រ ។

ដំណាំនេះគេប្រើជីមានច្រើនដំណាក់កាលដូចជា៖មុនពេលដាំ (ទ្រាប់បាត) ប្រើជី ១៥.១៥.១៥ ចំនួន២០០គក្រ/ហត ក្រោយដាំរយៈពេល៧-១០ ថ្ងៃប្រើជីអ៊ុយរ៉េ ចំនួន៦៥គក្រ/ហ.ត ដោយលាយទឹកស្រោច ឬដាក់ក្បែរគុម្ព ហើយស្រោចទឹកក៏បាន ។ រយៈពេល៣អាទិត្យក្រោយដាំ គេដាក់ជីបំប៉ន ប្រភេទ ១៥.១៥.១៥ ចំនួន២០០គក្រ/ហត ដោយដាក់តាមចន្លោះគុម្ព ហើយលុបដីឲ្យជិតស្រោចទឹក ឲ្យជោគ។ លើកចុងក្រោយគឺដាក់ជីប្រភេទអ៊ុយរ៉េ ចំនួន៨៤គក្រ លាយជាមួយជីផូស្វាតចំនួន១០០គក្រ ដើម្បីដាក់លើផ្ទៃដី១ហ.ត នៅពេលត្រប់ចាប់ផ្តើមប្រមូលផល លើកទី១មានរយៈពេល៦៥-៧០ថ្ងៃ ក្រោយដាំ។

*៧.ការកំចាត់ស្មៅ*



ការកំចាត់ស្មៅ គឺគេចាប់ផ្តើមអនុវត្តតាំងពីចាប់ផ្តើមភ្ជួរដីមកដោយ

រាស់ប្រមូលដុតចោលទើបភ្ជួរដី។ ការដាំដុះលក្ខណៈទីផ្សារធំៗ

មុនរាស់យកស្មៅចេញគេប្រើថ្នាំសម្លាប់ស្មៅ**<u>គ្លីហ្វូសាត</u>** ឬ **<u>គ្លីស៊ីន៤៨</u>**

មួយហិកតាផ្ទៃដីប្រើ២,៥លីត្រ ។ វិធីប្រើគឺកំរិត ៦០-៧០សេសេ

លាយទឹក២០លីត្របាញ់លើផ្ទៃដី២០០ម²ក្រោយពីបាញ់រយៈពេល៧ថ្ងៃ ទើបចាប់ផ្តើមរាស់ប្រមូលផលយកស្មៅចេញហើយភ្ជួរហាលដី។ វិធីសាស្ត្រធ្វើដោយចបគឺក្រោយដាំ២អាទិត្យគេត្រូវជ្រំជ្រោយដីឲ្យផុសល្អ ហាលដី២ថ្ងៃ ទើបពូនរងឡើងវិញដើម្បីឲ្យស្មៅចង្រៃងាប់។ លើកទី២គេអាចជំរះយកស្មៅចេញតែមិនជ្រំជ្រោយដីឡើយ។

## IV.**អំពីជម្ងឺនិងវិធានការការពារ**

គ្រប់ជាប្រភេទដំណាំមួយដែលទទួលរងការបំផ្លាញពីជម្ងឺផ្សិតលើដើម ស្លឹក ឫស និងផ្លែ ។

-**<u>ជម្ងឺរលួយគល់កូនគ្រប់៖</u>** តាមធម្មតាជម្ងឺផ្សិតតែងតែកើតឡើងដោយលក្ខខណ្ឌអាកាសធាតុ និង បណ្តាលមកពីកត្តាសំណើមនៃដី។
ប្រភេទជម្ងឺរលួយគល់កូនគ្រប់នេះគឺបំផ្លាញកូនគ្រប់ទើបនឹងដុះរហូតដល់កូនគ្រប់មានសន្លឹកពិត
លក្ខណៈពិសេសរបស់វាគឺបណ្តាលមកពីដីដែលមានមេរោគ។

### **វិធានការការពារ៖**

ត្រូវបាចកំបោរចំនួន**២៥០ទៅ ៣៥០គក្រ/ហ.ត** ហើយភ្ជួរលុបរយៈពេលពីរសប្តាហ៍ទើបរៀបចំដីដាំ បាញ់ថ្នាំផ្សិតមួយអាទិត្យម្តងៗចាប់ពីសាបរហូតដល់គ្រប់ចេញផ្កានិងផ្លែ ។

## V.**អំពីសត្វល្អិត**

សត្វល្អិតដែលបំផ្លាញដំណាំគ្រប់មានពីរក្រុមធំៗ គឺ**<u>ក្រុមចោះ</u>** និង**<u>ស៊ីបំផ្លាញ</u>** ព្រមទាំង**<u>ក្រុមជញ្ជក់</u>** យករុក្ខរស។ ក្រុមស៊ីបំផ្លាញ ៖ ដង្កូវស៊ីរូងផ្លែ ដើម ស្លឹកដូចជា :

-**<u>ដង្កូវស៊ីរូងផ្លែនិងដើម</u>** ៖ លក្ខណៈនៃការបំផ្លាញ មេអំបៅគឺតែងពងដាក់ស្លឹក ផ្នែកខាងក្រោម រាយៗ ជាក្រុមខ្លះទៀតពងដាក់លើផ្កានិងដើម ក្រោយមកពងវាញាស់ហើយចោះចូលទៅក្នុងដើមផ្នែកខ្ចីនៃត្រួយ ឬក្តឹបខ្ចីៗធ្វើឲ្យត្រួយនៃដំណាំគ្រប់ស្រពោន ផ្លែគ្រប់ស្អុយមិនអាចលូតលាស់បាន ជាពិសេសវាបង្កកំណើតនៅលើគ្រប់ដំណាំអំបូរសូឡាណាសេ ធ្វើឲ្យវាមានលទ្ធភាពពង្រីកប្រជាករបានយ៉ាងលឿន ក្នុងលក្ខខណ្ឌអាកាសធាតុ ក្តៅ ។

ដើម្បីការពារទៅនឹងកត្តាចង្រៃបែបនេះ គេត្រូវអនុវត្តតាមវិធីសាស្ត្រច្រើនយ៉ាងដូចជា ៖

ជ្រើសរើសពូជធន់ទ្រាំល្អ រៀបចំដីឲ្យត្រឹមត្រូវ ផ្លាស់ប្តូរមុខដំណាំ ជ្រើសរើសរដូវដាំឲ្យមានចន្លោះជួរ និងគុម្ពឲ្យបានត្រឹមត្រូវ កាត់រំលោះស្លឹកចោលខ្លះ សំអាតស្មៅក្នុងចំការព្រមទាំងវិធានការគីមី ដើម្បីរួមផ្សំពេលសត្វល្អិតទើបនឹងកើត ។

## V.**ការប្រមូលផល**

គ្រប់អាចប្រមូលផលបានក្រោយពីដាំរយៈពេលខុសៗគ្នាទៅតាមប្រភេទរបស់គ្រប់និងប្រភេទរបស់ ពូជ ។

-ប្រភេទគ្រាប់ផ្លែខ្លីដូចជា គ្រាប់ពងមាន់ គ្រាប់ក្រាំងរមាស និងគ្រាប់សណ្តាយផ្លែខ្លី គឺចន្លោះពី៧០-៧៥ថ្ងៃ ហើយការប្រមូលផលអាចច្រើនលើកអាស្រ័យទៅលើការថែទាំជាពិសេសគឺការកាត់ស្លឹកចាស់ចោល ដាក់ជីបន្ថែម និងស្រោចទឹក។ ចំពោះទិន្នផលជាមធ្យមគ្រាប់ក្រាំងរមាសគឺ**១១-១៣តោន/ហ.ត** គ្រាប់ពងមាន់ចន្លោះពី

**៨-១០តោន/ហ.ត** រីឯគ្រាប់សណ្តាយផ្លែខ្លីចន្លោះពី **៧ទៅ៩តោន/ហ.ត** ។

-ប្រភេទគ្រាប់សណ្តាយផ្លែវែងអាចមានអាយុប្រហែលគ្នានឹងគ្រាប់ខាងលើដែរ អាស្រ័យទៅតាមប្រភេទពូជពូជទំនើបចន្លោះពី៦៥ទៅ៧៥ថ្ងៃ ពូជក្នុងស្រុកចន្លោះពី៧៥ទៅ៨០ថ្ងៃ រីឯទិន្នផលចន្លោះពី **៨ទៅ១៣តោន/ហ.ត** ។ គ្រាប់អាចប្រមូលផលបានច្រើនសារអាស្រ័យលើការថែទាំ និងការកាត់ស្លឹកចាស់ៗចោលនៅ ពេលវាបន្ថយផ្កា ។ ដើម្បីឲ្យផ្លែគ្រាប់រក្សាបាននូវសោភ័ណភាពល្អនិងគុណភាពគេតែងធ្វើការប្រមូលផលពេលព្រឹកព្រលឹម ឬល្ងាចត្រជាក់ក្រោយពីស្រោចទឹកហើយ ។ បេះហើយត្រូវយកទៅផ្សើមទឹកចំហាយបន្តិចៗ ទើបរៀបចំទុកដាក់ក្នុងឧបករណ៍ដឹកជញ្ជូន ។

# ដំណាំល្ពៅ

## I.ស្ថានភាពទូទៅ

ល្ពៅជាប្រភេទដំណាំបន្លែម្យ៉ាងដែលដុះលូតលាស់នៅលើពិភពលោកជាច្រើនពាន់ឆ្នាំកន្លងមក ហើយ ម្យ៉ាងទៀតវាក៏ត្រូវបានគេប្រើប្រាស់ជាបន្លែដ៏មានប្រជាប្រិយភាពនៅក្នុងជីវភាពប្រចាំថ្ងៃ ។

គេបានបែងចែកល្ពៅជាពីរប្រភេទគឺ:

-ល្ពៅផ្លែទ្រមៀច

-ល្ពៅផ្លែវែង ឬ ល្ពៅទ្រូ



តារាងទី១ : ការវិភាគអាហារូបត្ថម្ភទម្ងន់ ១០០ក្រាម បរិភោគបាន(១៩៧២,FAO)

| សារធាតុសំខាន់ៗ | ១០០ក្រាមចំអិន | |
|---|---|---|
| | ទង និងផ្កា | ផ្លែ |
| ថាមពល | ២១កាឡូរី | ២៧កាឡូរី |
| ជាតិទឹក | ៩២% | ៩១,៩% |
| ប្រូតេអ៊ីន | ៣,០ក្រាម | ០,៧ក្រាម |
| ប្រេង | ០,៩ក្រាម | ០,២ក្រាម |

| | | |
|---|---|---|
| ការបូអ៊ីត្រាត | ៣,០ក្រាម | ៦,៦ក្រាម |
| ជាតិសរសៃ | ០,៧ក្រាម | ០,៨ក្រាម |
| ជាតិផេះ | ១,០ក្រាម | ០,៦ក្រាម |
| កាល់ស្យូម | ៣៧មីលីក្រាម | ២៥មីលីក្រាម |
| ផូស្វាត | ៩៩មីលីក្រាម | ៣៣មីលីក្រាម |
| ដែក | ២,១០មីលីក្រាម | ០,៧មីលីក្រាម |
| អំបិល | ៦,០មីលីក្រាម | ៨,០មីលីក្រាម |
| ប៉ូតាស្យូម | ៤៧២មីលីក្រាម | ៣៥០មីលីក្រាម |
| ការូតែន | ១៩៤០មីលីស៊ីក្រាម | ៧៨៥មីលីស៊ីក្រាម |

ល្ពៅអាចដុះលូតលាស់បានពីតំបន់វាលទំនាបរហូតដល់ខ្ពង់រាប។ក្នុងករណីសីតុណ្ហភាពសមស្របធ្វើឲ្យបរិមាណផ្កាឈ្មោលនិងបរិមាណផ្កាញីមានអត្រាប្រហែលគ្នា ការរោយលំអងពីកេសរឈ្មោលទៅកេសរញីបានលឿនធ្វើឲ្យការបន្តពូជប្រព្រឹត្តទៅបានល្អ។ម្យ៉ាងវិញទៀតដំណាំប្រភេទនេះមិនទាមទារនូវសក្តានុពលនៃដីជាតិដីខ្លាំងក្លានោះឡើយ គេចាត់បញ្ចូលទៅក្នុងក្រុមធន់ទ្រាំនឹងដីអាស៊ីដ វាអាចដុះលូតលាស់បានលើដីដែលមានប៉េហាស់ ៥,៥-៧,០ហើយជ្រាបទឹកបានល្អ វាមិនទាមទារនូវអត្រាសំណើមខ្ពស់ដូចដំណាំងទៀតប៉ុន្មានទេ ព្រោះថាបើសំណើមកើនឡើងធ្វើឲ្យងាយនឹងកើត [illegible] ។



II.បច្ចេកទេសដាំដុះ

**១.*ការជ្រើសរើសពូជ***

នៅក្នុងវិស័យដាំដុះ ពូជដំណាំជាកត្តាសំខាន់ជាងគេ

ដូចនេះការជ្រើសរើសពូជត្រូវអនុលោមទៅតាមលក្ខណៈ សំខាន់ៗ ដូចខាងក្រោមៈ

***ក.អំពីប្រភេទពូជ:*** ពូជល្ពៅដែលប្រជាកសិករកំពុងធ្វើការដាំដុះមាន៤យ៉ាងគឺ:

***<u>ល្ពៅក្អែក ឬល្ពៅភ្នំ:</u>*** សំបកមានព័ណ៌ខ្មៅ ផ្លែមូលទ្រមៀចតូច សាច់ព័ណ៌លឿងចាស់ហើយក្រាស់ គ្រាប់តូចៗ មូលៗ សាច់ស្អិត ពូជនេះផ្លែច្រើនក្នុងមួយដើមៗ វាមានទងផ្លែតូចខ្លី ស្លឹកតូចល្អិតហើយមានរោមច្រើន គេឲ្យឈ្មោះ ថាល្ពៅភ្នំ ។ ប្រភេទពូជនេះធន់ទ្រាំ គេអាចដាំនៅរដូវភ្លៀងបាន ព្រោះវាធន់ទ្រាំទៅនឹងអាកាសធាតុក្តៅ ហើយមាន អាយុកាលលូតលាស់ខ្លី ។

***ល្ពៅពួង ឬ ល្ពៅល្អិត:***សំបកព័ណ៌ប្រផេះធម្មតា ផ្លែតូចទ្រមៀចទងធំៗ កទងវែង ដើមតូចល្អិត ថ្នាំងរង្វើល ស្លឹកតូចមូល រោមស្តើងហើយទន់ ស្លឹកបៃតងខ្ចី សាច់ហាប់ណែន ព័ណ៌លឿង ប៉ុន្តែផ្អែម គ្រាប់តូចសំប៉ែត សាច់មាន សរសៃបន្តិច ។ ពូជនេះ ភាគច្រើនដាំនៅតំបន់ខ្ពង់រាប និងវាលរាប ហើយនៅរដូវវស្សាវាធន់ទ្រាំទៅនឹងអាកាសធាតុក្តៅ គេហៅថាល្ពៅល្អិត ឬ ល្ពៅពួង។

***ល្ពៅទ្រូ និងល្ពៅហាប:*** ពូជនេះមានស្លឹកធំ ដើមធំថ្លោស ទងស្លឹកវែងៗ ស្លឹកធំ មូលទ្រវែងហើយស្តើង ព័ណ៌ បៃតងខ្ចី ផ្លែរង្វើលធំសាច់ស្តើង សំបកព័ណ៌ប្រផេះ ខ្លះមូលទ្រវែង ស្រួចក្បាល ស្រួចកន្ទុយ សាច់ព័ណ៌លឿងភ្លាវ ហើយ មានសរសៃច្រើន មិនហាប់ មិនស្អិតហើយមានជាតិផ្អែមទាប គ្រាប់របស់វាធំសំប៉ែតវែង។ ពូជប្រភេទនេះគេច្រើនតែដាំ នៅតាមតំបន់វាលទំនាប និងរដូវទឹកសំរក ព្រោះវាមិនធន់ទ្រាំនឹងអាកាសធាតុក្តៅ ។

### *ខ.លក្ខខណ្ឌនៃការជ្រើសរើស*

ការជ្រើសរើសពូជសម្រាប់ការដាំដុះត្រូវគិតពីលក្ខណៈសំខាន់ៗដូចតទៅ:

-ពូជធ្វើពាណិជ្ជកម្ម ជាពូជដែលផ្តល់ទិន្នផលខ្ពស់

-ពូជបង្កាត់សេរីអូភីវី
ឬពូជប្រពៃណីអាចទុកបន្តពូជទៅជំនាន់ក្រោយទៀតប៉ុន្តែកំរិតទិន្នផលទាបជាងពូជបង្កាត់។ ជាពិសេសគឺពូជដែលផ្តល់ទិន្នផលខ្ពស់សមស្របតាមតំបន់ ធន់ទ្រាំនឹងជម្ងឺសត្វល្អិតបំផ្លាញ ពេញនិយមនៃការប្រើប្រាស់ រីឯគ្រាប់ពូជមានសុខភាពល្អគ្មានជម្ងឺនិងសត្វល្អិតបំផ្លាញ ភាគរយនៃដំណុះគ្រាប់លើសពី ៨០%។

### *២.ការរៀបចំដី*



ល្ពៅអាចឆ្លើយតបទៅនឹងដីស្ទើរគ្រប់ប្រភេទ ប៉ុន្តែដីដែលមានជីជាតិទាប ធ្វើឲ្យល្ពៅឆាប់ងាប់ដើម ។ ប្រភេទដីដែលអំណោយផលដល់ដំណាំ ល្ពៅគឺដីល្បប់ល្បាយខ្សាច់ ដីក្រហម ឬដីខ្មៅ ប៉ុន្តែដីដែលជ្រាបទឹកមិនល្អ មិនអាចឲ្យល្ពៅ ទទួលបានទិន្នផលខ្ពស់ឡើយ ។ ម្យ៉ាងទៀតមិនត្រូវ ដាំល្ពៅក្រោយពីត្រសក់ ឪឡឹក ត្រឡាច។ ដើម្បីឲ្យការដាំដុះមាន លក្ខណៈងាយស្រួល ត្រូវភ្ជួរហាលដីឲ្យបានច្រើនសារ ហាលដីឲ្យបានយូរថ្ងៃ និងរាស់បំបែកដីឲ្យល្អិត ហើយលើករង ដែលមានទទឹង ១,៥ ទៅ ២ម៉ែត្រ កម្ពស់រង ២៥ ទៅ ៣០សង់ទីម៉ែត្រ



ពង្រាបរងឲ្យស្មើ ហើយកាប់រណ្ដៅ ចំកណ្ដាលរងជម្រៅ ២០សង់ទីម៉ែត្រ ចម្ងាយរណ្ដៅ១២០សង់ទីម៉ែត្របន្ទាប់មកយកជីធម្មជាតិគ្រប់ប្រភេទមកដាក់បាតរណ្ដៅឲ្យបានច្រើនហើយលប់ដីឲ្យជិតពីលើ ។

### *៣.វិធីសាស្ត្រដាំដុះ*

មុននឹងដាំយកគ្រាប់ពូជមកសំអាតជាមុន បន្ទាប់មកដាក់ហាលថ្ងៃឲ្យក្ដៅដើម្បីដាស់ដំណេកគ្រាប់ពូជហើយដាក់ត្រាំទឹកមួយយប់ក្រោយមកយកគ្រាប់ពូជទៅលាយជាមួយនឹងថ្នាំសម្លាប់ផ្សិតបន្តិចៗក្នុងកំរិត **<u>៣ក្រ,ស្មើ១គីឡូគ្រាប់ពូជ</u>** គេអាចយកគ្រាប់ល្ពៅទៅដាំក្នុងរណ្ដៅដែលបានកាប់ទុកជាមុនចំនួន៣-៤គ្រាប់ជម្រៅ២-៣សង់ទីម៉ែត្រក្នុង១ហិកតា គេដាំចំនួន**<u>៤៥៦៥រណ្ដៅ</u>** ឫគុម្ពដោយប្រើគ្រាប់ពូជចំនួន**<u>៤-៥ គ.ក្រ</u>**។

### *៤.ការជ្រំជ្រោយដី*

ជ្រំជ្រោយដីមានសារៈប្រយោជន៍ធ្វើឲ្យដីធូរបន្ថយការដុះស្មៅ បង្កឲ្យដីមានសំណើមគ្រប់គ្រាន់ងាយស្រួលដល់ការដុះ លូតលាស់ព្រមទាំងបំបាត់ជំរកសត្វផ្សេងៗ គេជ្រំដោយចប ដើម្បីបំផុសដី និងពូនគល់ក្រោយពីដាំរយៈពេល១៥-២០ថ្ងៃ។ ពេលនោះគេអាចដករំលោះកូនចេញដោយទុកតែ២-៣ ដើមក្នុង១គុម្ព។

### *៥.ការប្រើប្រាស់ដី*

ដើម្បីឲ្យការលូតលាស់បានលឿននិងការបន្តពូជបានល្អគេត្រូវបែងចែកការដាក់ជីជា៣លើក:

-<u>លើកទី១</u> យកជី ១៥.១៥.១៥ ចំនួន <u>១០០គីឡូក្រាម</u> លើផ្ទៃដី <u>១ហិកតា</u> មកដាក់រោយជុំវិញគល់ចំងាយ២០-៣០ សង់ទីម៉ែត្រ មុនពេលជ្រំជ្រោយដីលប់គល់បន្ទាប់មកជ្រំដីលប់និងពូនគល់ឡើង ។

-<u>លើកទី២</u> យកជីអ៊ុយរ៉េមកលាយជាមួយទឹកហើយស្រោចឲ្យជោគជុំវិញគល់ដោយប្រើ <u>១៥-២០ក្រាម</u> លាយទឹក <u>១៨-២០លីត្រ</u>។ សម្រាប់ផ្ទៃដីមួយហិកតាត្រូវប្រើក្នុងកំរិត <u>២៥-៣០ គីឡូក្រាម</u>ក្នុងមួយហិកតា។

-<u>លើកទី៣</u> យកជី១៥.១៥.១៥ ចំនួន ១០០គីឡូក្រាមលើផ្ទៃដី១ហិកតាមកដាក់ក្បែរគុម្ពចំងាយ ៣០ សង់ទីម៉ែត្រ ហើយកប់ដីឲ្យជិតពីលើ ដើម្បីឲ្យល្ពៅផ្លែបានច្រើន ហើយផ្លែលូតលាស់បានល្អរយៈពេល៤០ថ្ងៃក្រោយដាំ។

### *៦.ការស្រោចស្រព*

ល្ពៅជាប្រភេទដំណាំធន់ទ្រាំទៅនឹងកង្វះទឹក ឬភាពរាំងស្ងួត ប៉ុន្តែកាលណាវគ្គចេញផ្កាសំណើមដីមិនគ្រប់គ្រាន់ ធ្វើឲ្យថយចុះការបន្តពូជ បាត់បង់បរិមាណផ្លែយ៉ាងច្រើន ។ការស្រោចស្រពចែកចេញជា៣វគ្គធំៗ:

-<u>វគ្គលូតលាស់រហូតដល់ចេញផ្កាឈ្មោល:</u> វាត្រូវការទឹកជាមធ្យមរយៈពេល ៣-៤ថ្ងៃផ្តល់ទឹកម្តងប៉ុន្តែ សំណើមដីមិនត្រូវឲ្យលើសពី៦០-៦៥%។

-<u>វគ្គចេញផ្កាដល់ផ្លែ:</u> វគ្គនេះត្រូវផ្តល់ទឹកឲ្យបានគ្រប់គ្រាន់ដើម្បីឲ្យការបន្តពូជបញ្ចប់ព្រឹត្តទៅបានល្អ ត្រូវរក្សាសំណើមក្នុងកំរិតថេរពី ៧០-៧៥%។

-<u>វគ្គផ្លែចាស់និងទុំ</u>:
ការផ្តល់ទឹកត្រូវថយចុះមកវិញបន្តិចម្តងៗហើយផ្អាកទាំងស្រុងពេលល្ពៅចាប់ផ្តើមប្រមូលផលដំបូង។

III.អំពីជម្ងឺនិងសត្វល្អិត

### ១.*អំពីជម្ងឺសំខាន់ៗ*

ល្ពៅក៏ដូចជាដំណាំឯទៀតដែរតែងតែទទួលរងនូវជម្ងឺជាច្រើនប្រភេទដែលបង្កដោយក្រុមជម្ងឺនិងវីរុស។

### *ក.ជម្ងឺបង្កឡើងដោយផ្សិត*

-<u>ជម្ងឺរលួយគល់កូន</u>:វាបង្កឡើងដោយភ្នាក់ងារបង្ករោគ៣ប្រភេទ:
ជម្ងឺប្រភេទនេះមេរោគភាគច្រើនរស់នៅជាមួយគ្រាប់ពូជនិងដីវាអាចឆ្លងនៅពេលកូនល្ពៅចាប់ផ្តើមដុះពន្លកធ្វើឲ្យកូនតូចៗរលួយគល់ក្នុងរយៈពេល៤-៧ថ្ងៃក្រោយដាំ។ ក្នុងករណីមានជម្ងឺប្រភេទនេះកើតឡើង ទោះជាវាមិនរលួយគល់ក៏វាធ្វើឲ្យកូនល្ពៅដុះលូតលាស់ខ្សោយនិងអាចធ្វើឲ្យល្ពៅងាប់ក្នុងពេលចេញផ្កា ។

-<u>ជម្ងឺពពាលលឿងស្លឹក</u>:
វាបង្កឡើងដោយភ្នាក់ងារបង្ករោគ។ជម្ងឺប្រភេទនេះតែងតែធ្វើឲ្យស្លឹកល្ពៅលឿងៗដុំៗ ហើយពពាលៗក្រោយមកធ្វើឲ្យស្លឹកស្ងួត វាតែងកើតឡើងនៅរដូវក្តៅ ។ រោគសញ្ញាកើតចេញពីស្លឹកក្រោមក្បែរដី រីករាលដាលឡើងមកស្លឹកលើ ក្នុងវគ្គចេញផ្កានិងផ្លែ ។

-<u>ជម្ងឺផ្សិតម្សៅលើស្លឹក</u>: វាបង្កដោយភ្នាក់ងារបង្ករោគ ។ ដំបូងសង្កេតឃើញចំណុចម្សៅៗជាដំណក់ៗនៅលើ ស្លឹក បន្ទាប់មកចំណុចដំណក់នោះរីកធំទៅៗហើយដុះចេញនូវម្សៅសៗពេញផ្ទៃស្លឹកបន្ទាប់មកហុយឆ្លងពីចំការមួយ ទៅចំការមួយ ធ្វើឲ្យស្លឹកស្ងួតអាចធ្វើឲ្យល្ពៅបន្ថយការបន្តពូជនិងផ្លែមិនរីកធំ មិនទុំពេញលក្ខណៈបាន។ ជម្ងឺប្រភេទនេះ កើតឡើងលើអំបូរត្រកូប៊ីតាសេ និងឡេគុយមីណឺ ។

-<u>ជម្ងឺរលួយគ្រឹប</u>: វាបង្កដោយភ្នាក់ងារបង្ករោគ ។ ជម្ងឺប្រភេទនះតែងធ្វើឲ្យមានការរំខានដល់ការបន្តពូជ មេរោគផ្សិតធ្វើឲ្យប៉ះពាល់ដល់កេសរញីនិងឈ្មោលធ្វើឲ្យផ្កាញីមិនអាចបន្តពូជបាន គ្រឹបមិនរីកធំ បន្ទាប់មកប្រែពណ៌ទៅជាលឿងហើយរលួយ

ជម្ងឺប្រភេទនេះកើតភាគច្រើននៅរដូវក្តៅហើយមានសំណើម។

-**<u>វិធានការការពារនិងកំចាត់</u>**: ភ្ជួរហាលដីឲ្យស្ងួតយូរថ្ងៃមុននឹងដាំ កំចាត់ស្មៅឲ្យស្អាត ផ្លាស់ប្តូរមុខដំណាំ សំអាតគ្រាប់ពូជមុនដាំ ជ្រើសរើសពូជធន់ទ្រាំនិងជ្រើសរើសរដូវដាំដុះ ។ ជាពិសេសត្រូវយកគ្រាប់ពូជទៅលាយ ជាមួយថ្នាំសម្លាប់ផ្សិតមុនដាំ។ម្យ៉ាងទៀតគេត្រូវយកថ្នាំផ្សិតមកលាយទឹកបាញ់ឲ្យជោគក្រោយពីកូនល្ពៅដុះពន្លក ព្រមទាំងបាញ់ទប់ទល់ រយៈពេល៤-៧ ថ្ងៃម្តងពេលមានរោគសញ្ញាដំបូង ។

### *ខ.ជម្ងឺបង្កឡើងដោយវីរុស*

មានជម្ងឺវីរុសជាច្រើនប្រភេទដែលកើតនៅលើដំណាំល្ពៅដូចជា

-ជម្ងឺរួញត្រួយៈជម្ងឺនេះបង្កឡើងពីរុយស

-ជម្ងឺរួញស្លឹក : បង្កឡើងពីខ្មុងតូចៗស្លាបរឹងនិងឆ្លងតាមរយៈគ្រាប់ពូជដែលធ្លាប់ទទួលរងការបំផ្លាញពីជម្ងឺប្រភេទនេះពីមុនមក ។ ជម្ងឺប្រភេទនេះអាចកើតឡើងនៅលើផ្លែល្ពៅធ្វើឲ្យផ្លែប្រែប្រួលទម្រង់សំបកក្រាស់ខុសពីធម្មតា ហើយក្រិនមិនធំធាត់ឡើយ ។

-ជម្ងឺគឿនិងពកឫស : ជម្ងឺប្រភេទនេះគេតែងសង្កេតឃើញកើតនៅក្នុងវគ្គលូតលាស់ធ្វើឲ្យដើមល្ពៅប្រែពណ៌ទៅជាពណ៌បៃតងក្រមៅ ហើយរួញគឿលែងលូតលាស់។

### *<u>វិធានការការពារ និងកំចាត់សត្វល្អិត</u>*

-ជ្រើសរើសពូជសុទ្ធគ្មានសត្វល្អិតនិងជម្ងឺបំផ្លាញ ប្តូរដីនិងផ្លាស់មុខដំណាំ និងដកដើមដែលមានជម្ងឺវីរុសទៅដុតចោល

### *២.អំពីសត្វល្អិតចង្រៃ*

មានសត្វល្អិតចង្រៃជាច្រើនប្រភេទដែលស៊ីបំផ្លាញនិងចម្លងមេរោគ ដូចនេះគេចែកចេញជា២ផ្នែកគឺ:

### *ក.សត្វល្អិតនិងភ្នាក់ងារបង្ករោគ*

សត្វល្អិតចង្រៃប្រភេទនេះជាច្រើនដូចជា ចៃបៃតងជញ្ជក់ស្លឹក មមាចជញ្ជក់ស្លឹក ខ្មុងពពាលតូចៗតែងបង្កឲ្យ កើតជម្ងឺវីរុសច្រើនប្រភេទ ។

*ខ.សត្វល្អិតបំផ្លាញផ្ទាល់*

មានសត្វល្អិតបំផ្លាញជាច្រើនប្រភេទដែលតែងស៊ីស្លឹកផ្កា ផ្លែនិងដើមដូចជា:

-អណ្តើកមាសពណ៌លឿង:
វាស៊ីត្រួយខ្ចីៗផ្កាញីនិងផ្កាឈ្មោលធ្វើឲ្យល្ពៅថយចុះនូវការលូតលាស់និងបន្តពូជ ។

-ស្រឹងល្ពៅ: វាជញ្ជក់ស្លឹកនិងផ្កា ផ្លែតូចៗធ្វើឲ្យផ្លែលែងធំ ហើយស្អុយលែងលូតលាស់ ។

-រុយទិចផ្លែ: រុយប្រភេទនេះទិចបញ្ចូលពងទៅក្នុងផ្លែធ្វើឲ្យផ្លែរលួយមិនធំបាន

-ដង្កូវកាត់ដើម: ដង្កូវប្រភេទនេះវាកាត់គល់កូនដំណាំខ្ចីៗក្នុងវគ្គលូតលាស់ដំបូង ។

-ដង្កូវចោះផ្លែ: ដង្កូវប្រភេទនេះវាកកេរស៊ីផ្លែ ដើម ស្លឹក គ្រប់វគ្គលូតលាស់ដំណាំ ។

**<u>វិធានការការពារ:</u>**

**វិធានការតាមបែបជីវសាស្រ្ត:**

ត្រូវសំអាតស្មៅក្នុងចំការ ដាំឲ្យមានចន្លោះគុម្ពនិងជួរឲ្យបានសមស្រប ផ្លាស់ប្តូរមុខដំណាំ ហាលដីឲ្យបានយូរ ខែ ជ្រើសរើសពូជដែលសមស្របទៅនឹងតំបន់ដាំដុះ ។

**វិធានការតាមបែបគីមី :**

ត្រូវរោយថ្នាំហ្វូរ៉ាដង់ជុំវិញគល់អាចយកថ្នាំគីមីលាយទឹកបាញ់ ពេលសត្វល្អិតមិនទាន់ពេញវ័យ ។

IV.ការប្រមូលផល

ការប្រមូលផលធ្វើឡើងខុសៗគ្នាទៅតាមប្រភេទពូជនិងតម្រូវការទីផ្សារ។ផ្លែល្ពៅទុំដំបូងត្រូវប្រមូលទុកមុនគេ។លក្ខណ:សំគាល់គឺផ្លែល្ពៅឡើងពណ៌ប្រផេះ ស្រអាប់ សំបករឹង ត្រូវកាត់ផ្លែល្ពៅទាំងទងយកមកទុកលើធ្នើរ មិនប៉ះដីទើបរក្សាបានយូរខែ ។ ជាធម្មតាល្ពៅក្អែកនិងល្ពៅពួងទិន្នផលមធ្យមពី **<u>១៤ ទៅ ១៦ តោន/ហ.ត</u>** ប៉ុន្តែល្ពៅទ្រូនិងល្ពៅ ហាប ទិន្នផលជាមធ្យមពី **<u>១៨ ទៅ ២២តោន/ហ.ត</u>** ដើម្បីរក្សាទុកពូជឲ្យបានល្អគេបេះផ្លែទុំពេញលក្ខណៈពីដើមដែលគ្មានកើតជម្ងឺមករក្សាទុកពី១០ ទៅ១៥ថ្ងៃ បន្ទាប់មកពុះផ្លែហើយយកគ្រាប់មកលាងទឹកឲ្យស្អាត ដាក់ហាលថ្ងៃឲ្យ ស្ងួតក្នុងថ្ងៃដំបូងតែ២ថ្ងៃ បន្ទាប់មកគេត្រូវហាលគ្រាប់ល្ពៅនឹងខ្យល់ស្ងួតមិនឲ្យត្រូវកំដៅថ្ងៃ កាលណាហាលថ្ងៃក្តៅខ្លាំងធ្វើឲ្យគ្រាប់ល្ពៅ រក្សាភាពរស់មិនបានយូរខែ ។ បន្ទាប់ពីបានគ្រាប់ហើយ គេត្រូវច្រកនឹងឧបករណ៍ចម្លងកំដៅ និង សំណើម ព្រមទាំងរក្សាទុកនៅកន្លែងស្ងួតហើយត្រជាក់ធម្មតា ។

# ដំណាំត្រសក់ចំណារ

## I.ស្ថានភាពទូទៅ

ដំណាំត្រសក់ត្រូវបានគេជឿជាក់ថា មានប្រភពនៅប្រទេសឥណ្ឌា ក្រោយមកក៏រីករាលដាលទៅប្រទេស អេស៊ីប ប្រទេសក្រិច ចិន ឥណ្ឌូនេស៊ី ប្រទេសថៃ និងនៅទ្វីបអាមេរិក ។





ដំណាំប្រភេទនេះ គេចាត់បញ្ចូលទៅក្នុងដំណាំត្រូវការអាកាសធាតុក្តៅមធ្យមចន្លោះ១៨-៣០ºC

-ត្រសក់ចំណារស្ថិតក្នុងលំដាប់គ្រួសារគូកូប៊ីតាសេ ។ គេចែកចេញជាពីរប្រភេទគឺ ប្រភេទសំបករលោង និង សំបកគ្រើម ។ វាជាប្រភពនៃវីតាមីន និងសារធាតុរ៉ែផ្សេងៗក្នុងទម្ងន់១០០ក្រាមដែលអាចបរិភោគបានផ្លែខ្ចី ដូចជាៈ

| សារធាតុសំខាន់ៗ | ក្នុងទម្ងន់១០០ក្រាមដែលអាចបរិភោគបាន |
|---|---|
| ទឹក | ៩៦,៣ក្រាម |
| ប្រូតេអ៊ីន | ០,៤៤ក្រាម |
| ប្រេងខ្លាញ់ | ០,៥ក្រាម |
| ថាមពល | ១៣គីឡូកាឡូរី |
| កាល់ស្យូម | ១០មីលីក្រាម |
| ផូស្វាត | ២៥មីលីក្រាម |
| ដែក | ១,៥មីលីក្រាម |
| វីតាមីនសេ | ៧មីលីក្រាម |

## II.បច្ចេកទេសដាំដុះ

ដើម្បីទទួលបានទិន្នផលពីការដាំដុះ ដំណាំត្រសក់ក៏ដូចដំណាំឯទៀតដែរ ត្រូវមានការងារច្រើនដែលត្រូវអនុវត្ត ដូចតទៅ ៖

### *១.ការជ្រើសរើសពូជ*

ការជ្រើសរើសពូជជាកត្តាសំខាន់បំផុតនៅក្នុងការដាំដុះព្រោះពូជមានលក្ខខណ្ឌផ្សេងៗពីគ្នា ហើយត្រូវបានចែកចេញជា៣ប្រភេទ ដូចតទៅ ៖







***-ពូជស្រាល:***ពូជនេះមានអាយុកាលលូតលាស់ខ្លីគឺប្រមាណពី **៣៥-៤០ថ្ងៃ**ក្រោយដាំ ភាគច្រើនគឺផ្លែល្អិតតូចៗ ជាចង្កោមៗមានបន្លាច្រើនជួរតាមបណ្ដោយនៃផ្លែ ទទឹងផ្លែមិនលើស ១,៥ស.មប្រវែងជាមធ្យម ៨-១០ស.ម ។ សន្លឹកល្អិតដើមតូចផ្កាឈ្មោលច្រើនតាមថ្នាំងនៃដើម ហើយមានរោមក្រាស់លើផ្ទៃស្លឹកនិងដើម គ្រាប់តូចល្អិតស្រួចៗ ហើយខ្លីទម្ងន់ ១០០គ្រាប់មានចំនួន ២,៥-៤ ក្រាម ប្រភេទនេះគេឲ្យឈ្មោះថា **ត្រសក់បន្លា ឬត្រសក់ជ្រក់**។





***-ពូជកណ្ដាល:***ពូជនេះមានអាយុកាលលូតលាស់មធ្យម គឺប្រមាណពី **៤០-៥០ថ្ងៃក្រោយដាំ**។ ផ្លែភាគច្រើនមានព័ណ៌បៃតងស្រាល ផ្នែកខាងគូទមានព័ណ៌លឿងខ្ចី ផ្លែច្រើនរាយៗ មិនចង្កោម ទទឹងផ្លែមានប្រវែង៣-៤ស.ម បណ្ដោយផ្លែប្រវែងពី ១០-១៣ស.ម រាងរបស់ផ្លែវាធំកណ្ដាល តូចក្បាលនិងកន្ទុយ ពូជនេះកសិករភាគច្រើនដាំនៅ

តាមស្ទួនបន្លែ មិនមានលក្ខណៈទ្រង់ទ្រាយជាផលិតកម្មធំៗឡើយ ព្រោះទិន្នផលរាប់ពី**<u>៦-៨តោនក្នុង១ហិកតា</u>**។ លក្ខណៈសំគាល់គឺ ស្លឹកធំ ស្តើងរាងមូល រោមខ្លីៗមានព័ណ៌បៃតងធម្មតា គ្រាប់សំប៉ែតធំខ្លី ។

***-ពូជធូន់.***ពូជនេះមានអាយុកាលលូតលាស់វែងប្រមាណពី **៥០-៧០ថ្ងៃក្រោយដាំ**។ ផ្លែរបស់វាទ្រវែងមានព័ណ៌បៃតងចាស់ប្រមាណ២/៣នៃប្រវែងផ្លែ ។ មានថ្នាំងរង្វើលបែកមែកមធ្យម ស្លឹកធំក្រាស់ហើយស្រួច មានរោមរឹងទទឹងផ្លែជាមធ្យម ៣,៥ស.ម ប្រវែងជាមធ្យម ១២-២០ស.ម រូបសណ្ឋាននៃគ្រាប់ទ្រវែងស្រួច កំប៉ោងកណ្តាល ទម្ងន់១០០គ្រាប់ពី**<u>៣,៥-៥,៥ក្រាម</u>** ច្រើនដាំនៅខេត្តកណ្តាល កំពង់ឆ្នាំង និងកំពង់ចាម ។ ត្រសក់មិនមែនជាដំណាំប្រកាន់រដូវឡើយ ប៉ុន្តែពូជត្រសក់ក្រោយពីសំរាំងគ្រាប់ហើយត្រូវការសំរាករយៈពេលពី**៤-៦ខែទើបអាចដាំដុះបាន** ។ លក្ខណៈពិសេសមួយទៀតគឺបច្ចុប្បន្នមានពូជ២ប្រភេទគឺ ពូជគ្មានជំនាន់ អាចដាំបានហើយទុកពូជបាន ប៉ុន្តែពូជបង្កាត់មិនអាចទុកពូជបានឡើយ ។ សេចក្តីត្រូវការពូជសម្រាប់ដាំលើផ្ទៃដី១ហ.ត គឺ **<u>៣,៥ ទៅ ៥គ.ក្រ</u>** អាស្រ័យទៅតាមភាគរយដំណុះនិងចន្លោះគុម្ពនៃការដាំ ។

***២.ការជ្រើសរើសរដូវ***

-សម្រាប់លក្ខខណ្ឌប្រទេសកម្ពុជា ដំណាំត្រសក់មិនមែនជាដំណាំដែលប្រកាន់រដូវឡើយ វាអាចដុះលូតលាស់បានចន្លោះសីតុណ្ហភាពពី២០-៣០ºC ។ ប៉ុន្តែរដូវសមស្របបំផុតគឺនៅចុងរដូវវស្សាចាប់ពីខែតុលា ដល់ខែ កុម្ភៈ ព្រោះក្នុងអំឡុងពេលនោះ ត្រសក់អាចលូតលាស់ល្អ ទិន្នផលខ្ពស់បណ្តាលមកពីកត្តាសីតុណ្ហភាពចុះទាប សំណើមបរិយាកាសខ្ពស់ ភ្លៀងមិនអូសបន្លាយ សីតុណ្ហភាពដីប្រែប្រួលទាប រយៈពេលពន្លឺថ្ងៃមានកំរិតសមស្រប ។ ប៉ុន្តែត្រសក់ជួបកត្តាលំបាកជាច្រើន ចាប់ពីខែមីនា ដល់ខែ ឧសភា គឺសត្វល្អិត ជម្ងឺបំផ្លាញច្រើនបណ្តាលមកពីលក្ខខណ្ឌអាកាសធាតុមិនសមស្របធ្វើឲ្យត្រសក់មានទិន្នផលទាប ។ តែនៅរដូវវស្សាវិញចាប់ពីខែ មិថុនា ដល់ខែ កញ្ញា ត្រសក់ច្រើនជួបជម្ងឺបំផ្លាញច្រើនជាងសត្វល្អិត បណ្តាលមកពីសំណើមដីនិងសីតុណ្ហភាពដីប្រែប្រួល ។

***៣.ការជ្រើសរើស និងរៀបចំដី***

*-ការជ្រើសរើសដី*

ត្រសក់ត្រូវការដីមានជីជាតិគ្រប់គ្រាន់ សំបូរទៅដោយសារធាតុចិញ្ចឹម និងបន្ទុកខ្យល់គ្រប់គ្រាន់សម្រាប់ ត្រសក់គឺដីប្រភេទដីល្បប់មាត់ស្ទឹង បឹង ទន្លេនិងដីល្បាយខ្សាច់មិនដក់ទឹកក្រោយពេលភ្លៀងធ្លាក់ កាលណាទឹកដក់ លើសពី៤ម៉ោងឡើងទៅធ្វើឲ្យត្រសក់ងាយកើតជម្ងឺទុំស្លឹក ។ ក្រៅពីនោះ វាអាចលូតលាស់ល្អដែរនៅលើប្រភេទ ដីក្រហម និងដីខ្មៅក្នុងតំបន់ខ្ពង់រាប ប៉ុន្តែដីឥដ្ឋ ឬដីជូរត្រសក់លូតលាស់មិនល្អឡើយ។ កាលណាដីដែលធ្លាប់ដាំដំណាំ ប្រភេទអំបូរត្រសក់ជាច្រើនលើករួចមក គេត្រូវបន្ថែមជីលាមកសត្វជាច្រើនតោនក្នុង១ហិកតា ចន្លោះពី២០-៣០តោន ។ ដីដែលសមស្រប

ខ្លាំងមានប៉េហាស់ ៦,៥-៧,៥ កាលណាប៉េហាស់**ទាបជាង៤** ត្រូវផ្អាកការដាំត្រសក់រយៈពេល១-២ឆ្នាំ ត្រូវដាំដំណាំអំបូរសណ្តែកដើម្បីកែលំអដី ។

***-ការរៀបចំដី:***ត្រូវរាស់ប្រមូលយកស្មៅនិងដំណាំផ្សេងៗពីរដូវមុនចេញ ភ្ជួរហាលដីលើកទី១ ឲ្យជ្រៅត្រឡប់ស្រទាប់ដីពីក្រោមឡើងលើ និងហាលដីឲ្យបានច្រើនសប្តាហ៍ក្នុងគោលបំណងបន្ថយនូវភ្នាក់ងារចម្លងជម្ងឺ និង សត្វល្អិតព្រមទាំងឲ្យស្មៅចង្រៃងាប់ ជាពិសេសគឺប្តូរទម្រង់ដីនិងពង្រាយជីជាតិ ។ ការភ្ជួរត្រូវធ្វើឲ្យបាន២-៣លើកមុននឹងលើករងដាំដុះ ។ ការលើករងសម្រាប់ដាំគឺអាស្រ័យទៅតាមវិធីដាំនិងជីជាតិរបស់ដី ។ កាលណាដាំដោយដោតចំណារបញ្ឈរទទឹងរងត្រូវមានប្រវែង១២០ស.ម កំពស់រង ២៥-៣០ស.ម ។ ប៉ុន្តែបើដាំឲ្យវារនៅលើដី ទទឹងរងមានប្រវែង៨០ ទៅ ១០០ស.ម តែការដាំតាមវិធីនេះត្រសក់មានផ្លែចំនួនតិច ទិន្នផលទាប ។ នៅក្នុងលក្ខខណ្ឌអាកាសធាតុក្តៅ ដីរក្សា សំណើមគ្របដីមុនពេលដាំដើម្បីបន្ថយកំដៅដី ស្មៅរក្សាសំណើមបានយូរនិងឲ្យដីធូរមិនហាប់ កាលណាដីហាប់បណ្តាលឲ្យបន្ទុកខ្យល់មិនគ្រប់គ្រាន់ និងប្រវែងឫសចាក់បានតិច ។

## ***៤.វិធីសាស្ត្រដាំដុះ***

មុននឹងដាំ ត្រូវយកគ្រាប់ពូជមកដាក់ហាលថ្ងៃឲ្យក្តៅរយៈពេល១-២ម៉ោង បន្ទាប់មកយកទៅត្រាំទឹករយៈពេល ៤ ទៅ៥ម៉ោង បន្ទាប់ត្រូវលាងសំអាតគ្រាប់ឲ្យស្អាត ចំនួន ៣-៤លើកមុនពេលផ្អាប់ត្រាំគ្រាប់ពូជ ។ ការផ្អាប់ត្រូវយកក្រណាត់ជ្រលក់ទឹកឲ្យជោកយកមកខ្ចប់គ្រាប់នោះហើយកប់ទៅក្នុងដីសើមៗរយៈពេល១យប់ ។ មុនដាំត្រូវយកគ្រាប់ ពូជមកលាយជាមួយនឹងថ្នាំសម្លាប់ផ្សិតប្រភេទ កាប់តង់,ស៊ីណែប,ម៉ង់កូសែប **ក្នុងកំរិត២% ឬ ១គក្រគ្រាប់ពូជបរិមាណថ្នាំកន្លះស្លាបព្រាបាយ** ច្របល់ឲ្យសព្វយកទៅដាំដោយប្រើចន្លោះគុម្ព២៥ស.ម ចន្លោះជួរ៦០ស.ម ជម្រៅ២-៣ស.ម គ្រាប់ក្នុងមួយគុម្ពហើយគ្របពីលើដោយកំណាត់ចំបើងខ្លីៗ ឬជីធម្មជាតិពុករលួយល្អ វិធីនេះគឺដាំឲ្យត្រសក់ ឡើងតោងចំណារបញ្ឈរ ប៉ុន្តែការដាំឲ្យវារលើដីត្រូវប្រើចន្លោះជួរ៨០ស.ម ចន្លោះគុម្ព ៥០ស.ម, ៣-៤គ្រាប់ ក្នុង មួយគុម្ព តែគ្រប គុម្ពដូចគ្នា ។ ក្រោយពីដាំភ្លាមត្រូវពិនិត្យមើលសំណើមដីកាលណាដីស្ងួតខ្លាំងត្រូវតែស្រោចទឹក ក្រោយដាំហើយដើម្បីឲ្យត្រសក់ដុះស្មើគ្នាងាយថែទាំ ។ ក្រោយពីដាំរយៈពេល៣ទៅ៤ថ្ងៃក្នុងលក្ខខណ្ឌអាកាសធាតុពេលថ្ងៃ៣០អង្សាសេ និងពេលយប់១៨-២០អង្សាសេ ធ្វើឲ្យត្រសក់លូតលាស់លឿន។





### *៥.របៀបស្រោចស្រព*

-ដំណាំត្រសក់ជាប្រភេទដំណាំត្រូវការទឹកជាប្រចាំ ប៉ុន្តែសំណើមដីមិនលើសពី៥០-៧០%ឡើង ។ សេចក្ដីត្រូវការទឹកចែកចេញជាបីវគ្គ ៖

**-វគ្គលូតលាស់:**ចាប់ពីត្រសក់ដុះរហូតដល់ត្រសក់បោះដៃ និងមានផ្កាក្រពុំវាត្រូវការសំណើមដីជាមធ្យមប្រមាណ ពី៥០-៦០% ។ របៀបស្រោចដោយបាញ់ទឹកពីលើល្អជាងការ ស្រោចដោយបញ្ចូលតាមចន្លោះជួរ គឺ១ថ្ងៃម្ដង ឬ ២ដងទៅតាមប្រភេទដី និងអាកាសធាតុ បរិមាណទឹកក្នុងវគ្គនេះ មានប្រមាណពី **១៤០០ - ១៦០០ម$^{៣}$/ហ.ត** ។

**-វគ្គបន្តពូជនិងផ្លែ:**ចាប់ពីត្រសក់មានអាយុពី១៥ថ្ងៃឡើងទៅវានឹងមានផ្កាឈ្មោលចេញតាមថ្នាំង ប៉ុន្តែមិន ទាន់រីក។ វគ្គនេះត្រូវការសំណើមដីពី ៦០-៧០% គឺជាវគ្គដែលត្រូវការទឹកច្រើនជាងគេ រហូតដល់ត្រសក់មានអាយុ ៣០-៤០ថ្ងៃក្រោយដាំ ប៉ុន្តែការស្រោចដោយបញ្ចូលតាមចន្លោះរងមួយអាទិត្យ២-៣លើកជាការល្អ ព្រោះការស្រោចដោយបាញ់ទឹក ពីលើធ្វើឲ្យប៉ះពាល់ដល់ការបន្តពូជបរិមាណទឹកសរុបក្នុងវគ្គនេះមានពី**១៨០០ទៅ ២០០០ម$^{៣}$/ហ.ត** ។

**-វគ្គចេញផ្លែ:**១០០% ចាប់ពីការប្រមូលផល១-២លើកត្រសក់ត្រូវការសំណើមដីទាបមកវិញ គឺពី ៥០-៦៥ % កាលណាការបញ្ចូលទឹកលើសពីនេះធ្វើឲ្យត្រសក់ចាប់ប្រែព័ណ៌ពីបៃតងទៅលឿង ។

### *៦.ដកស្មៅនិងជ្រំជ្រោយដី*

ការជ្រំជ្រោយដីត្រូវធ្វើឡើងនៅពេលត្រសក់មានសន្លឹកពិតចំនួន ២ គឺនៅពេលទងរបស់វាលូតវែង ( ១០-១៥ថ្ងៃក្រោយដាំ)ត្រូវជ្រំបំបែកដីសើរៗហើយកៀរយកដីពីបាតរងមកលប់គល់ឲ្យជិតក្នុងករណីដីដែលដុះស្មៅត្រូវដកយកស្មៅចេញមុនជ្រំជ្រោយដី ។ ចំពោះការដាំដោយគ្របនឹងកៅស៊ូខ្មៅមិនចាំបាច់ជ្រំជ្រោយដីឡើយ ។ ការជ្រំជ្រោយដីគឺប្រយោជន៍ធ្វើឲ្យដីធូរ ជ្រាបទឹកបានល្អ រក្សាសំណើមបានយូរ ធ្វើឲ្យខ្យល់ចេញចូលបានល្អបន្ថយការលូតលាស់ របស់ស្មៅ។

### *៧.ការដោតចំណារ*

ការដោតចំណារមានសារៈសំខាន់ដោយបង្កើនទិន្នផលនិងបន្ថយការរាតត្បាតអំពីជម្ងឺនិងសត្វល្អិត ។ ការដោតចំណារត្រូវយកមែកឈើក្រៀមៗគ្មានស្លឹកមកដោតបញ្ឈរក្បែរៗគុម្ពឲ្យញឹកហើយចងឲ្យជាប់ការការពារដួលរលំ គេធ្វើឡើងក្រោយពីដាំរយៈពេល១០-១៥ថ្ងៃគឺក្រោយពីជ្រំជ្រោយដី ។

### *៨.ការប្រើប្រាស់ជី*

ដំណាំត្រសក់ក៏ដូចដំណាំឯទៀតដែរ វាត្រូវការសារធាតុចិញ្ចឹម៣យ៉ាងសំខាន់គឺ អាសូត ផូស្វ័រ ប៉ូតាស្យូម និងសារធាតុផ្សេងៗទៀត ។ ប៉ុន្តែសារធាតុទាំងនោះ វាត្រូវការទៅតាមដំណាក់កាលរបស់វាដូចជា ដំណាក់កាលលូតលាស់ដើម ស្លឹក វាត្រូវការអាសូតច្រើនជាងគេ បន្ទាប់មកគឺធាតុប៉ូតាស្យូម ប៉ុន្តែផូស្វ័រវាត្រូវការបន្តិចម្តងៗចាប់ ពីវគ្គកំណកំណើតផ្កា ដោយបរិមាណក្នុងមួយវដ្តជីវិតតិចជាងគេ។ ដូចនេះការប្រើប្រាស់ជីត្រូវដាក់ទៅតាមដំណាក់ កាលរបស់វា ៖

-មុនពេលដាំគេតែងដាក់ជីធម្មជាតិឲ្យបានច្រើនពី១៥ទៅ២០តោនក្នុង១ហិកតានិងជីគីមីប្រភេទ១៥.១៥.១៥ ចំនួន១៥០គក្រ។ ជីទាំងនោះត្រូវដាក់ទៅក្នុងបាតរណ្តៅហើយជ្រំដីលប់ឲ្យជិតពីលើទើបធ្វើការដាំដុះតាមក្រោយ ។

-ក្រោយពេលដាំរយៈពេល១០ទៅ១៥ថ្ងៃគេត្រូវយកជីអាសូតសុទ្ធ(អ៊ុយរ៉េ)ចំនួន២៥ទៅ៣០គក្រមកលាយ ទឹកស្រោចចំៗគុម្ព បន្ទាប់មកស្រោចទឹកលាងតាមក្រោយ ។

-នៅក្នុងវគ្គត្រសក់ចេញផ្កា១០០%គេយកជីគីមីប្រភេទ១៥.១៥.១៥ដដែលចំនួន១០០គក្រមកដាក់តាមចន្លោះគុម្ព ហើយលប់ដីឲ្យជិត បន្ទាប់មកស្រោចទឹកឲ្យជោគ ។

## III.**អំពីជម្ងឺនិងសត្វល្អិត**

### ***១.អំពីជម្ងឺផ្សិត***

-ត្រសក់រងការបំផ្លាញដោយជម្ងឺផ្សិតច្រើនប្រភេទ ហើយគ្រប់វគ្គលូតលាស់វគ្គបន្តពូជ និងវគ្គទុំនៃផ្លែ ។

**✶ជម្ងឺរលាកនៃគល់កូនដំណាំ:**វាបង្កដោយក្រុមផ្សិតច្រើនប្រភេទរោគសញ្ញាគឺចាប់ផ្តើមរលាកគល់ដំណាំក្នុង ដំណាក់កាល ៥-៧ថ្ងៃក្រោយដុះធ្វើឲ្យរលាកជាំៗគល់ ក្រោយមកក៏ចាប់ផ្តើមដួលរលំ ហើយរីករាលដាលកាន់តែច្រើនឡើងៗលើរងកូនដំណាំ ។ លក្ខខណ្ឌគឺកូនដំណាំស្តោកជាប់មកជាមួយគ្រាប់ដីថ្នាលសំណាបមានមេរោគ សំណើមដី ខ្ពស់លើសពី ៧០% គ្មានខ្យល់អាកាស និងពន្លឺគ្រប់គ្រាន់ ។

**✶ជម្ងឺស្ងួតស្លឹកពណ៌ត្នោត:**

-**<u>រោគសញ្ញា</u>**:ដំបូងស្លឹកត្រសក់ឡើងលឿងផ្ទាំងៗក្រោយមកទៅជាស្ងួតហើយប្រែពណ៌ទៅត្នោតប្រផេះ ពីស្លឹកក្រោមឡើងមកលើ ធ្វើឲ្យស្លឹកដំណាំស្ងួតពីដើមមួយទៅដើមមួយ ហើយរីករាលដាលយ៉ាងរហ័ស ។

-**<u>លក្ខខណ្ឌបំផ្លាញ</u>**: នៅរដូវវស្សាភាគច្រើនជាងរដូវប្រាំង បណ្តាលមកពីសំណើមដីខ្ពស់អាកាសធាតុក្តៅ ចន្លោះគុម្ពញឹក ចំនួនដើមក្នុងគុម្ពលើសកំណត់ ពន្លឺមិនគ្រប់គ្រាន់ ខ្យល់អាកាសមិនល្អ ។

**✶ជម្ងឺរលួយឫស និងស្ងួតបណ្តូលនៃដើម**

-**<u>រោគសញ្ញា</u>**:ក្នុងដំណាក់កាលកូនដំណាំខ្ចីៗធ្វើឲ្យស្វិតរញូមស្រពោនពីមួយថ្ងៃទៅមួយថ្ងៃកាន់តែស្រពោន ឡើងៗ ដើមរបស់ដំណាំស្ងួតបណ្តូល ឫសរបស់វាប្រេះហើយជាំៗ ។

-**<u>លក្ខខណ្ឌបំផ្លាញ</u>**:ជម្ងឺរស់នៅក្នុងដី និងទឹក ហើយវាឆ្លងពីចំការមួយទៅចំការមួយ ពីដើមមួយទៅដើមមួយ ដោយទឹក និងកាកសំណល់ដំណាំ អាកាសធាតុក្តៅ និងសំណើមដីខ្លាំងលើសពី៧៥%ងាយនឹងកើត ។

**✶ជម្ងឺក្រាម្សៅលើស្លឹក :**

-**<u>រោគសញ្ញា</u>**: ដំបូងសង្កេតឃើញលេចចេញចំណុចពណ៌លឿងតូចៗលើស្លឹក ក្រោយមកមានស្នាមម្សៅកញ្ចុំៗ រាងរង្វង់រយៈពេលតែ២ទៅ៣ថ្ងៃរង្វង់ម្សៅនេះរីករាលដាលពេញស្លឹក ទាំងស្លឹកខ្ចីក៏ដូចស្លឹកចាស់ ។

-**<u>លក្ខខណ្ឌកំណើត</u>**:ច្រើនកើតនៅរដូវប្រាំងពេលអាកាសធាតុត្រជាក់ស្ងួតមេរោគចូលចិត្តរស់នៅតាមដើមឈើព្រៃ និងឈើហូបផ្លែ រដូវភ្លៀងមិនធ្វើឲ្យមានលក្ខណៈធ្ងន់ធ្ងរឡើយ ។

**២-ជម្ងឺបង្កឡើងដោយវីរុស**

-ជម្ងឺដែលបង្កដោយវីរុសមានច្រើនប្រភេទលើដំណាំត្រសក់ដូចជា :

**✶ជម្ងឺរួញស្លឹកខ្សូរចុះក្រោម :**

-<u>រោគសញ្ញាដំបូង</u> វាលេចចេញចំណុចខ្លះនៅលើស្លឹកគឺសភាពរួញជាពិសេស ស្លឹកខ្ចីៗ ក្នុងដំណាក់កាលលូតលាស់ធ្វើឲ្យមិនអាចរីកធំធាត់បាន ព្រមទាំងធ្វើឲ្យផ្លែពកៗក្រឡាៗ ហើយរឹងសំបក សាច់ត្រសក់គ្មានរសជាតិវារីកនិងរាលដាលចម្លងដោយក្រុមចៃ ។

វិធានការការពារនិងកំចាត់: គឺជ្រើសរើសពូជគ្មានជម្ងឺ កំចាត់ស្មៅឲ្យស្អាត និងការពារចៃកុំឲ្យបំផ្លាញត្រសក់ ។

**៣-សត្វល្អិត:**

មានសត្វល្អិតចង្រៃជាច្រើនប្រភេទដែលបំផ្លាញដំណាំក្នុងនោះមានសត្វល្អិតជាភ្នាក់ងារបង្ករោគនិងសត្វល្អិតបំផ្លាញផ្ទាល់ ។ សត្វល្អិតជាភ្នាក់ងារចម្លងមាន :

**-ចៃបៃតង:**រោមជញ្ជក់ស្លឹកធ្វើឲ្យត្រសក់រួញស្លឹកហើយខ្សូរចុះក្រោម

**-មមាចជញ្ជក់ស្លឹក:**វាមានពីរប្រភេទ មាឌតូច និងមាឌធំតែងជញ្ជក់ស្លឹកធ្វើឲ្យស្លឹកត្រសក់ស្ងួតគែមហើយស្លឹក ឡើងលើ ។

**-រុយស:** រុយប្រភេទនេះមានមាឌតូចៗពណ៌ស ហើយមើលនឹងភ្នែកទទេស្ទើរមិនឃើញ គេអាចសង្កេតវាបាន ដោយត្រូវពិនិត្យមើលក្រោមស្លឹកពេលថ្ងៃក្តៅ ។

ដើម្បីការពារទៅនឹងកត្តាចង្រៃទាំងនេះ គេត្រូវអនុវត្តវិធីសាស្ត្រច្រើនយ៉ាងដូចជា ជ្រើសរើសរដូវ ផ្លាស់ប្តូរ មុខដំណាំ ជ្រើសរើសពូជធន់ទ្រាំ រៀបចំដីឲ្យបានត្រឹមត្រូវ សំអាតស្មៅក្នុងចំការ ជាពិសេសគ្រប់គ្រងវត្តមានសត្វល្អិត មុនពេលវាពេញវ័យ បន្ទាប់មកអនុវត្តវិធានការដើម្បីកំចាត់ ។





IV.**ការប្រមូលផល**

**១-ការប្រមូលផល**

-ការប្រមូលផលគឺធ្វើឡើងក្រោយពីការដាំរយៈពេលខុសគ្នា ទៅតាមប្រភេទពូជ និងអាស្រ័យទៅតាមសេចក្តីត្រូវការដូចជា:

**<u>-ពូជស្រាល</u>**:គឺគេអាចប្រមូលផលដំបូងក្រោយពីការដាំរយៈពេល៣៥ទៅ៤០ថ្ងៃគឺបេះផ្លែដោយយកកន្ត្រៃកាត់ត្រឹមទងនៃផ្លែ ហាមប្រឡេះយកតែផ្លែបណ្តាលឲ្យផ្លែត្រសក់ឆាប់ក្រហមប្រែពណ៌ ប្រភេទពូជនេះទិន្នផលមធ្យម ចន្លោះពី ៨- ១០តោន ក្នុងមួយហិកតា។

**<u>-ពូជកណ្តាល</u>**:គឺការប្រមូលផលដំបូងក្រោយដាំរយៈពេល៤៥ទៅ៥០ថ្ងៃ ការបេះគឺកាត់យកផ្លែដូចជា ត្រសក់ ឯទៀតដែរ ។ ការបេះយកផ្លែស្រស់មានចំនួនពី**<u>៥ទៅ៧លើក</u>** ហើយទិន្នផលជាមធ្យម១០ ទៅ ២០ តោនក្នុង១ហ.ត។

**<u>-ពូជធ្ងន់</u>**:ធ្វើការប្រមូលផលបានច្រើនលើកពី**<u>៥ ទៅ ១០លើក</u>** ហើយទិន្នផលមធ្យមពី**<u>១០ទៅ១៥តោន</u>**ក្នុងមួយ ហិកតា ។





**២-ការប្រមូលផលពូជ:**

ដើម្បីឲ្យពូជនៅជំនាន់ក្រោយទទួលបាន ភាពសុទ្ធល្អការជ្រើសរើសត្រូវអនុវត្តទៅតាមវិធីសាស្រ្តខាងក្រោម ៖

-ដើមគ្មានជម្ងឺ និងសត្វល្អិតបំផ្លាញ

-ដើមលូតលាស់ធម្មតា មានលក្ខណ:តែមួយផ្នែកសំខាន់:គឺថ្ងៃ ខែ ចេញផ្កា ស្លឹកពណ៌ និងទ្រង់ទ្រាយផ្លែមានលក្ខណ:ដូចគ្នាទាំងពណ៌និងទំហំ ។ ផ្លែដែលមុនគេ(ផ្លែដំបូង)ត្រូវកាត់ចោលទុកតែផ្លែលើកទី២ទី៣ ក្រៅពីនេះកាត់ ចោល ហើយផ្លែទាំងនោះត្រូវបេះមកទុកដោយឡែកៗពីគ្នា គឺទី២ទុកដោយទី២ ទី៣ទុកដោយទី៣ នៅពេលផ្លែទុំ ក្រហមប្រេះបែកក្រឡា ក្រោយពីបេះហើយត្រូវរក្សាទុកពី៤ទៅ៥ថ្ងៃទើបពុះផ្លែយកគ្រាប់ត្រាំទឹកមួយយប់ បន្ទាប់មក លាងទឹកសំអាត យកគ្រាប់ដែលល្អមមកដាក់ហាលថ្ងៃរយ:ពេល១ទៅ២ថ្ងៃ (ហាមហាលថ្ងៃត្រង់និងលើឧបករណ៍ ដែក) ក្រោយមកទុកគ្រាប់ឲ្យត្រជាក់ទើបប្រមូលយកគ្រាប់ដាក់ដប ឬកញ្ចប់ហើយបិទជិត រក្សាទុកនៅកន្លែងស្ងួតធម្មតាហាមត្រូវកំដៅថ្ងៃ ។

---

# ជំណាំស្ពៃចង្កឹះ

ស្ពៃចង្កឹះជាដំណាំបន្លែមួយប្រភេទក្នុងចំណោមបន្លែស្លឹកជាច្រើនដែលកសិករយើងនិយមចូលចិត្តដាំ ព្រោះវាជាបន្លែសាមញ្ញមួយអាចយកមកប្រើប្រាស់ក្នុងការធ្វើម្ហូបអាហារបានច្រើនមុខដូចជា : ស្ល ឆា ស្ងោរ ជ្រក ។ ល។ ដំបូងឡើយគេច្រើនតែដាំវានៅក្នុងសួនបន្លែជាលក្ខណៈគ្រួសារតូចៗតែបច្ចុប្បន្នស្ពៃចង្កឹះបានក្លាយទៅជាប្រភេទបន្លែយ៉ាងពេញនិយមធ្វើអោយកសិករយើងផលិតជាច្រើនតំបន់ ហើយលាតសន្ធឹងលើផ្ទៃដីកាន់តែច្រើនឡើងៗ ទាំងរដូវប្រាំង និងរដូវ វស្សា ។

ជាទូទៅស្ពៃចង្កឹះអាចលូតលាស់ស្មើរគ្រប់រដូវ ប៉ុន្តែនៅរដូវត្រជាក់វាលូតលាស់ជាងរដូវក្តៅ ហើយពុំសូវមានសត្វល្អិតចង្រៃស៊ីបំផ្លាញទៀតផង ។

ប្រភេទបន្លែនេះអាចលូតលាស់បានលើដីគ្រប់ប្រភេទដូចជា : ដីខ្មៅ ដីក្រហម ដីល្បាយខ្សាច់និងដីល្បប់តាមមាត់ទន្លេព្រែក និងស្ទឹង។ ជាពិសេសដីដែលសំបូរទៅដោយជាតិអាសូតធ្វើអោយដំណាំបន្លែដុះ លូតលាស់លឿន ទទួលបានទិន្នផលខ្ពស់ ។ វាសំបូរទៅដោយជីវជាតិច្រើនដូចជា : ជាតិប្រូតេអ៊ីន វីតាមីនអា បេ សេ ព្រមទាំងជាតិរ៉ែ ផ្សេងៗទៀតដូចជា : ជាតិកាល់ស្យូម ដែក ផូស្វ័រ និងជាតិប៉ូតាស្យូម ។ល។




## ១. ការជ្រើសរើសពូជ :

ពូជជាកត្តាមួយយ៉ាងសំខាន់ដែលអាចកំណត់ទិន្នផល ។ ដូច្នេះយើងត្រូវការស្គាល់ពូជអោយបានច្បាស់លាស់មុន ធ្វើការដាំដុះ។ នៅប្រទេសកម្ពុជាយើងបច្ចុប្បន្ននេះ បច្ចេកវិទ្យានៃការបង្កាត់ពូជនៅមានកំរិតទាប ដូចនេះកសិករយើង តែងតែទុកពូជដោយខ្លួនឯងគឺជាពូជនៅក្នុងស្រុក ពូជនេះពុំទាន់ទទួលបានទិន្នផលខ្ពស់ដូចពូជបង្កាត់ឡើយ ។នៅប្រទេស កម្ពុជាយើងលក្ខខណ្ឌអាចទុកពូជបានគឺនៅរដូវរំហើយ ចំពោះរដូវវស្សា ការទុកពូជមិនអាចធ្វើទៅបានទេ ពីព្រោះទឹកភ្លៀង និងអាកាសធាតុមានឥទ្ធិពលអាក្រក់ដល់ការបន្តពូជរបស់ស្ពៃ ។ គ្រាប់ពូជដែលត្រូវជ្រើសរើសយកមកដាំត្រូវមានលក្ខណៈដូចខាងក្រោម :

- ដុះលូតលាស់សមស្របនឹងតំបន់ផលិត ហើយមិនប្រកាន់រដូវ
- ផ្តល់ទិន្នផលខ្ពស់ រយៈពេលលូតលាស់ខ្លី
- ពេញនិយមក្នុងការប្រើប្រាស់លើទីផ្សារ
- ធន់ទ្រាំនឹងជម្ងឺសត្វល្អិតបំផ្លាញ
- គ្រាប់ពូជសុទ្ធ គ្មានជម្ងឺ សត្វល្អិតបំផ្លាញ ភាគរយដំណុះខ្ពស់ ។

## ២. ការរៀបចំដី

ដំណាំបន្លែ ទាមទារការរៀបចំដីអោយបានស្អាតល្អ គឺដីស្ងួតភ្ជួរអោយបានជ្រៅ រាស់បំបែកដីអោយម៉ត់ ធ្វើយ៉ាង ណាអោយដីធូរ ងាប់ស្មៅចង្រៃ និងសត្វល្អិតរស់នៅក្នុងដី ។ កាលណារៀបចំដីមិនបានត្រឹមត្រូវ បណ្តោលអោយកើតជម្ងឺ និងសត្វល្អិតបំផ្លាញច្រើន ជានិច្ចជាកាលដំណាំប្រភេទនេះត្រូវការទឹកជាប្រចាំ ដូចនេះចំការស្លែត្រូវមានប្រភពទឹកគ្រប់គ្រាន់សំរាប់ស្រោចស្រព ទោះជាតំបន់វាលទំនាប និងខ្ពស់រាបក៏ដោយ ។




### ក. ការរៀបចំថ្នាលសាបកូន :

- ការធ្វើថ្នាលសាបកូន :រដូវប្រាំង យើងត្រូវជ្រើសរើសដីមានជីជាតិល្អ ឆ្ងាយពីម្លប់ឈើ ស្ថិតនៅក្បែរផ្ទះនិង មានរបងការពារ ។ ដំបូងត្រូវភ្ជួរ និងកាប់ដីអោយជ្រៅ ហាលដីអោយបានស្ងួត រយៈពេលពី ៣-៧ថ្ងៃ ក្រោយពីដីភ្ជួរ ហើយត្រូវវាយ ឬ រាស់បំបែកដីឱ្យម៉ត់ លើកជាថ្នាលដែលមានទទឹងពី ៦០-៨០ ស.ម កម្ពស់ពី ១០-១៥ ស.ម បណ្តោយផ្អែកទៅតាមស្ថានភាពជាក់ស្តែង របស់ដីចន្លោះថ្នាលពី ៣០-៤០ ស.ម កៀរពង្រាបដីឱ្យស្មើល្អ ធានារក្សា សំនើមបានយូរ ធ្វើឱ្យកូនស្លែលូតលាស់ស្មើគ្នាល្អ ។

- ការធ្វើថ្នាលសាបកូននៅរដូវវស្សា : មិនខុសពីរដូវប្រាំងឡើយ តែយើងត្រូវរកទីកន្លែងទួលខ្ពស់មិនជាំទឹក ក្រោយពេលភ្លៀងត្រូវភ្ជួរ ឬ កាប់ដីហាលឱ្យបានយូរថ្ងៃជាងរដូវប្រាំង ហើយត្រូវមានគំរបការពារទឹកភ្លៀងគ្រប់ដីឱ្យស្ងួត ចន្លោះពី ៧ថ្ងៃ ជ្រួយដីហាលឱ្យបានច្រើនសារ បន្ទាប់មកលើកជារងឱ្យបានខ្ពស់ពី ១៥-២០ ស.ម ទទឹងពី ៨០-១០០ ស.ម ចន្លោះពីថ្នាលមួយទៅថ្នាលមួយពី ៣០-៤០ ស.ម ថ្នាលសាបកូនត្រូវកៀរដីឱ្យបានស្មើរ មានប្រឡាយបញ្ចេញទឹក ។




### ខ. ការរៀបចំដីសំរាប់ស្ទូង

- <u>នៅរដូវវស្សា</u> : ការរៀបចំថ្នាលសំរាប់ស្ទូង គឺ ត្រូវភ្ជួរដីឱ្យបានជម្រៅពី ១៥-២០ ស.ម ហើយហាលដីឱ្យស្ងួតរយៈពេលពី ៥ ទៅ ៧ថ្ងៃ ទើបរាស់បំបែកដីប្រមូលយកស្មៅចេញ បន្ទាប់មកហាលដីឱ្យបានស្ងួតបាន ២-៣ ថ្ងៃ ។ ក្រោយមកទៀតភ្ជួរប្រែដីហាលឱ្យបាន រយៈពេល ៣-៥ ថ្ងៃ ទើបរាស់ និងកៀរឱ្យស្មើល្អ ។

- <u>របៀបលើករង</u> : គេលើករងដោយប្រើនង្គ័លគោភ្ជួរផ្គុំគ្នា ។ ម្យ៉ាងទៀតលើកដោយប្រើចបឆាយតាម បណ្តោយខ្សែបន្ទាប់ក្រោយពីភ្ជួរផ្គុំ ឬ លើកដោយចបហើយត្រូវកៀររងនីមួយៗឱ្យស្មើគ្នា ក្បាលរងត្រូវឱ្យត្រឹមគ្នាដែល មានទទឹងពី ៨០-១០០ ស.ម បណ្តោយជាការល្អត្រូវមានប្រវែង ១០-២០ ម៉ែត្រ កម្ពស់រងពី ១៥-២០ ស.ម ។

- <u>រដូវប្រាំង</u> : ការរៀបចំដីស្ទូងនៅរដូវប្រាំង គឺធ្វើឡើងផ្សេងៗ ពីគ្នាទៅតាមប្រភេទដី និង តំបន់ដាំដុះ នៅតំបន់ដីល្បប់តាមមាត់ទន្លេ ក្រោយពីទឹកស្រកផុត ដីចាប់ផ្តើមស្ងួត ៥០% គេត្រូវភ្ជួរហាលដីដោយនង្គ័លគោរយៈ ពេល ៤-៥ថ្ងៃក្រោយមករាស់ដីឱ្យម៉ត់ និងធ្វើឱ្យបានច្រើនលើក បន្ទាប់មកហាលដីរយៈពេល ២-៣ ថ្ងៃ ឱ្យដីស្ងួត ងាប់ស្មៅហើយ និងសំរាមដុតចោល ។ បន្ទាប់មកទៀត ទើបភ្ជួរប្រែដី និងរាស់ជាបន្តបន្ទាប់គឺធ្វើឱ្យបានចំនួន ២-៣លើក ឱ្យម៉ត់ល្មម និងធ្វើឱ្យទឹកជ្រាបបានរហ័ស ។ ចំពោះដីមិនលិចទឹកត្រូវរាស់ប្រមូលយកស្មៅ និងកាកសំណល់ផ្សេងៗចេញ បន្ទាប់មកចាប់ផ្តើមភ្ជួរហាលដីឱ្យបាន៣-៤ថ្ងៃ ក្រោយមកកិនបំបែកដីឱ្យម៉ត់ ហើយរាស់ជួយដីឱ្យធូរ ឡើងវិញ ទើបភ្ជួរប្រែដី និងហាលដីចោលរយៈពេល៥-៧ថ្ងៃ ។ នៅពេលដីស្ងួតចាប់ផ្តើមភ្ជួររាស់ដីឱ្យស្មើចំនួន ២-៣លើក បន្ទាប់មកចាប់ផ្តើមលើករងដែលមានទទឹង និង បណ្តោយដូចគ្នាទៅនឹងរដូវវស្សាប៉ុន្តែកំពស់រងពី១០-២០ស.ម ។ រងនីមួយៗត្រូវមានសភាពស្មើគ្នា ។

## ៣. បច្ចេកទេសដាំដុះ

ដំណាំស្ពៃចង្កឹះគេអាចដាំបានតាម២វិធីគឺៈ ការសាបកូនហើយដក ទៅស្ទូង និងការព្រួសដោយគ្រាប់ផ្ទាល់ក៏បាន។

**ក. របៀបសាបគ្រាប់ពូជ :** មុនពេលសាបគ្រាប់ពូជត្រូវយកដីកំប៉ុស្ត ឬ ជីលាមកសត្វចំនួន ២បង្គី ឬ ៣០Kg ទៅបាចលើថ្នាល ដែលមានផ្ទៃដី ១០-១៥ ម៉ែត្រការ៉េ រួចហើយយកជី ១៥.១៥.១៥ ចំនួន ២០០ ក្រាម ឬប្រាំស្លាបព្រាបាយ និង ថ្នាំ Furadan 3Hចំនួន៥០ក្រាម ទៅបាចពីលើថ្នាលហើយរាស់លុបទៅក្នុងដី ក្រោយមកស្រោចទឹកឱ្យជោគ គ្រាប់ពូជត្រូវយកមកត្រាំជាមួយទឹកដែលបានលាយជាមួយថ្នាំ Captan ៥ក្រាម លាយជាមួយទឹក១លីត្រត្រាំរយៈពេល១០នាទី បន្ទាប់មកស្រង់ហាលគ្រាប់ឱ្យស្រស់ទឹកទើបយកទៅសាប ។ ត្រូវប្រើគ្រាប់ពូជចំនួនពី ១៥ ទៅ ១៦ ក្រាម ឬ ១ស្លាបព្រាបាយ ក្នុងផ្ទៃដី ១០ ម៉ែត្រការេ ។

ក្រោយសាបរួចហើយ ព្រាចកំណាត់ចំបើងស្ងួតខ្លីៗ ឱ្យពេញលើថ្នាលហើយស្រោចទឹកឱ្យជោគ ទើបគ្របស្លឹកចេកពីលើបន្ទាប់មកស្រោចទឹករាល់ថ្ងៃ គឺមួយថ្ងៃ២លើក ព្រឹក-ល្ងាច ។ រយៈពេលក្រោយសាបចំនួន២យប់ត្រូវបកស្លឹកចេកនោះចេញពេលនោះកូនស្ពៃចាប់ផ្តើមដុះ ។

**ខ. របៀបស្ទូង**

ក្រោយពីសាបរយៈពេល ១៤-១៦ថ្ងៃ កូនស្ពៃមានស្លឹក ៣ កំពស់ពី ៨-១០ស.ម គេអាចដកកូនស្ពៃទៅស្ទូងបាន ។ នៅមុនពេលដកកូនស្ពៃត្រូវស្រោចទឹកឱ្យជោគរយៈពេល ២០-៣០នាទី ចំពោះថ្នាលសំរាប់ស្ទូង ដំបូងត្រូវយកជីធម្មជាតិពុកផុយល្អចំនួន២បង្គី ស្មើនឹង ៣០ Kgជី ១៥.១៥.១៥ ចំនួន២០០ក្រាម ស្មើនឹង២ខាំ ទៅបាចលើរងប្រវែង ១០-១៥ម៉ែត្រ ហើយរាស់លុបទៅក្នុងដី បន្ទាប់មកស្រោចទឹកឱ្យជោគទើបស្ទូងតាមក្រោយ ។ ជាការល្អត្រូវស្ទូងពេលថ្ងៃរសៀលត្រជាក់ ។ រីឯចន្លោះគុម្ព និងចន្លោះជួរដែលត្រូវស្ទូងគឺ ២៥ x ២០ ស.ម ក្រោយស្ទូង ហើយត្រូវស្រោចទឹកឱ្យជោគ។ ដើម្បីបន្ថយកំដៅដី និងការពារការហាប់ដី ព្រមទាំងអាចរក្សាសំណើមដីបានយូរ ចាំបាចត្រូវព្រោចកំណាត់ចំបើងស្ងួតឱ្យសព្វល្អពេញលើផ្ទៃរងហើយស្រោចទឹក៣ដងក្នុងមួយថ្ងៃស្រោចក្នុងរយៈពេល ៣ថ្ងៃ ក្រោយស្ទូង ។

**គ. របៀបដាំដោយសាបគ្រាប់ផ្ទាល់ :**

ក្រោយពីការរៀបចំរងហើយ ត្រូវយកជីកំប៉ុស្តិនិងជី ១៥.១៥.១៥.ចំនួនដូចខាងលើមកព្រោចលើថ្នាលហើយរោយថ្នាំ Furadan3Hចំនួន៣ស្លាបព្រាបាយ ហើយរាស់លុបទៅក្នុងដី បន្ទាប់មកស្រោយទឹកឱ្យជោគ ។ ចំពោះគ្រាប់ពូជដែលយកមកព្រួសឱ្យរង្វើល១ ក្នុងកំរិតកន្លះស្លាបព្រាបាយ ស្មើនឹង៨ក្រាមលើផ្ទៃថ្នាល១០ម៉ែត្រការេ ។ ក្រោយពីព្រួសហើយត្រូវព្រោចកំណាត់ចំបើងស្ងួតពីលើទើបស្រោចទឹកតាមក្រោយ ។ដើម្បីឱ្យកូនស្ពៃដុះស្មើគ្នាល្អរយៈពេល ២-៣ថ្ងៃដំបូងត្រូវស្រោចទឹក៣ដងក្នុងមួយថ្ងៃ។ ក្រោយពេលកូន ស្ពៃដុះបានរយៈពេល៧-១០ថ្ងៃ គេត្រូវដករំលោះកូនស្ពៃចេញខ្លះនៅត្រង់កន្លែងដែលញឹកពេក គឺត្រូវរក្សាទុកចំនួនដើមស្ពៃត្រឹមតែ ២០-២៥ ដើមក្នុងមួយម៉ែត្រការេ។





## ៤. ការថែទាំ :

**ក. ការស្រោចស្រព :** ការស្រោចស្រពអាចធ្វើបានច្រើនរបៀបគឺ ស្រោចដោយប៉ោតមួយថ្ងៃស្រោច២លើក ព្រឹកល្ងាច។ ដំណាំស្ពៃចង្កឹះមិនត្រូវការទឹកច្រើនពេកទេ តែវាត្រូវការជាប្រចាំរៀងរាល់ថ្ងៃ ។ បច្ចុប្បន្នកសិករអាចស្រោច ស្រពដោយម៉ាស៊ីន

គឺដាក់ជំពួយផ្កាឈូកបាញ់ឱ្យជោគ១ថ្ងៃម្តង តែវិធីនេះធ្វើឱ្យដីឆាប់ហាប់កាលណាគេស្រោចដោយម៉ាស៊ីនបាញ់ ចាំបាច់ត្រូវគ្រប់ចំបើងឱ្យក្រាស់ ។





**ខ. ការដាក់ជី :** ស្ពៃចង្កឹះជាបន្លែដែលត្រូវការជាចាំបាច់នូវជីជាតិអាសូតផូស្វាត និងប៉ូតាស្យូម ។ ប៉ុន្តែសេចក្តីត្រូវការនេះត្រូវបែងចែកទៅតាមដំណាក់កាលលូតលាស់របស់វា ។ ប្រភេទបន្លែស្លឹកត្រូវការជាតិអាសូតច្រើនជាងគេ ដូច្នេះការដាក់ជីត្រូវធ្វើឡើងដោយអនុលោមទៅតាមប្រភេទដី ។ ក្រោយសាបបានពី ១០-១២ថ្ងៃ ត្រូវយកជីអ៊ុយរ៉េចំនួន ១ស្លាបព្រាបាយលាយទឹក២០លីត្រ ស្រោចលើស្លែរង ១០-១៥ម៉ែត្រការ៉េ ហើយត្រូវស្រោចលាងតាមក្រោយឱ្យជោគ ។ នៅពេលកូនស្ពៃមានអាយុពី ១៥-២០ថ្ងៃត្រូវយកជី ១៥.១៥.១៥ ចំនួន២ខាំកន្លះ បាចលើផ្ទៃថ្នាល ១០-១៥ ម៉ែត្រការេ បើប្រើលើផ្ទៃដី១ ហ.ត ត្រូវប្រើក្នុងកំរិត ១៥០ -២០០Kg ដោយរោយតាមចន្លោះគុម្ពហើយស្រោយទឹកឱ្យជោគភ្លាមៗ ។ បន្ទាប់មកទៀតរយៈពេលមួយសប្តាហ៍ម្តង ប្រើជីអ៊ុយរ៉េ តាមកំរិតដូចមុន ។ ចំពោះការដាំដោយស្ទូង ក្រោយពីស្ទូងកូនរយៈពី ៧-១០ថ្ងៃ យើងត្រូវយកជីអ៊ុយរ៉េចំនួន១ស្លាបព្រា លាយទឹក ២០ លីត្រស្រោចលើផ្ទៃដី ១០- ១៥ ម៉ែត្រការ៉េ រយៈពេល១សប្តាហ៍ម្តងៗ ។

### គ. ការសំអាតស្មៅជ្រំដីពូនគល់ :

ស្មៅជាកត្តាចង្រៃ វាជាជំរកសត្វល្អិត ដណ្តើមទឹក ពន្លឺ និងជីជាតិពីដំណាំ ។ អ្នកត្រូវដកស្មៅចេញដោយប្រើកូនចបតូចៗ រយៈពេលពី ៧-១០ថ្ងៃក្រោយសាប ឬស្ទូង ត្រូវដកស្មៅជ្រំជ្រួយដីឱ្យធូរដើម្បីរក្សាសំនើមបានល្អ ។ មួយអាយុកាលរបស់ស្ពៃអ្នកអាចដកស្មៅចំនួន <u>២-៣ លើក</u> ។ ចំពោះការជ្រំជ្រួយដីធ្វើឡើង តែមួយលើកតែ ប៉ុណ្ណោះ ។

### ឃ. អំពីសត្វល្អិត និង វិធានការការពារ

- **អំពីជម្ងឺសំខាន់ ១ :** ជម្ងឺដែលតែងតែកើតលើដំណាំស្ពៃចង្កឹះភាគច្រើនជា <u>ជម្ងឺផ្សិត និងជម្ងឺបាក់តេរី</u> ។ ជម្ងឺនេះធ្វើឱ្យស្លឹកស្ពៃមានចំណុចអុចសៗហើយស្ងួតព្រមទាំងរលួយស្លឹកផ្នែកខាងលើក្រោយមករីករាលពាសពេញផ្ទៃរង កូនស្ពៃ ។ ជម្ងឺរលួយគល់ស្ពៃដែលបណ្តាលមកពីបាក់តេរីភាគច្រើនធ្វើឱ្យរលួយធាងស្ពៃក្បែរដី និងគល់ ។ លក្ខខណ្ឌដែល បណ្តាលឱ្យកើតជម្ងឺនេះ គឺអាកាសធាតុក្តៅខ្លាំង ដីសើមភ្លៀងធ្លាក់ច្រើន ។

**វិធានការការពារ និងកំចាត់ :** ត្រូវស្ងួងឱ្យរង្វើល ហាលដីឱ្យស្ងួតមុននឹងស្ទួង លាយថ្នាំនឹងគ្រាប់ពូជមុនពេលសាប ហើយបាញ់ថ្នាំផ្សិតប្រភេទ Captan ឬ Benomy1 កំរិតប្រើពី ២០-២០ក្រាមលាយទឹក១៥-២០លីត្រ មួយសប្តាហ៍បាញ់២ដង ហើយការស្រោចទឹក និង ដាក់ជី ។

## ង. អំពីសត្វល្អិត

-ដង្កូវឃោងទោង : ដង្កូវប្រភេទនេះជាសត្រូវបំផ្លាញយ៉ាងខ្លាំងចំពោះដំណាំអំបូរស្ពៃ ជាពិសេសនៅរដូវប្រាំង ពី ខែធ្នូ ឬ ខែកុម្ភៈ រហូតដល់ខែមេសា ។ វាស៊ីក្លូរភីល ដោយទុកតែភ្នាសស។ពេញលើផ្ទៃស្លឹក ។ មេអំបៅតែងតែចេញមកពងនៅពេលយប់នៅផ្ទៃកក្នុងស្លឹករយៈពេល ២០-៣០ ម៉ោង វានឹងញាស់បន្ទាប់មកចាប់ផ្តើមស៊ីបំផ្លាញ ។

- សត្វទាគួ : ដំបូងជាមេចំណាស់ ពងដាក់លើដីក្បែរគល់ដំណាំ ក្រោយពីពងរយៈពេល៣៥-៤២ម៉ោងវានឹងញាស់ ហើយចាប់ផ្តើមស៊ីឬសស្ពៃនៅក្នុងដីជាដំណាក់កាលដង្កូវ រយៈពេល១សប្តាហ៍ក្រោយមកវាចាប់ផ្តើមញាស់ទៅជាសត្វទាកគួ ហើយហើរជាហ្វូងមកចោះជញ្ជក់ស្លឹកធ្វើឱ្យស្លឹកស្ពៃធ្លុះលែងលូតលាស់ ។ លក្ខណៈរូបរបស់វា មានមាឌតូច ស្លាបពិណស ឬលឿងអមបណ្តោយស្លាបប្រវែង មិនលើសពី ២ម.ម ។

- ដង្កូវកាត់ដើម : មេអំបៅច្រើនពងដាក់គែម។ស្លឹកក្បែរដីក្រោយពីវាញាស់កូនដង្កូវទំលាក់ខ្លួនចូលទៅក្នុងដីនៅពេលយប់ដង្កូវចេញពីដីហើយកាត់បំផ្លាញគល់ស្ពៃឬស្លឹកស្ពៃ។ ការបំផ្លាញរបស់ដង្កូវប្រភេទនេះធ្វើឱ្យបាត់បង់ចំនួនដើមជាច្រើនក្នុងមួយថ្នាល។។

- ចៃបៃតង : ចៃប្រភេទនេះជញ្ជក់យករុក្ខរសពីស្លឹកស្ពៃ ធ្វើឱ្យស្ពៃរួញលែងលូតលាស់ ។ សញ្ញាសំគាល់នៅពេលមានចៃនៅក្នុងចំការ គឺមានស្រមោចឡើង ។

**វិធានការការពារ និងកំចាត់ :** វិធានការការពារតាមបែបជីវសាស្ត្រ : ត្រូវជ្រើសរើសរដូវដាំដុះ រៀបចំដីឱ្យបានល្អ កំចាត់ស្មៅស្រោចទឹកជាប្រចាំ ស្ទូងតាមចន្លោះគុម្ពតាមការកំណត់ ឆ្លាស់មុខដំណាំ និងប្រើវិធានការចំរុះការពារដំណាំ ។

វិធានការកំចាត់តាមបែបប្រើថ្នាំគីមី : មានថ្នាំពុលជាច្រើនប្រភេទ ដែលត្រូវយកមកប្រើដើម្បីកំចាត់សត្វល្អិតដូចជាថ្នាំ បេតេ (BT),វីតាហ្គ្រូ ( Vitagro),ឌីបភិល(Dipel) ហ្វូបាក់ (Florback), សេដាប់បែលយូ (CWD), សង់ដ័រ ( Zandor) សំរាប់តែដង្កូវឃោងទោង ។ ក្រៅពីនេះគេប្រើថ្នាំហ្វុយរ៉ាដង់ (Furadan 3H ) មកបាចដោយប្រើក្នុងកំរិត ១៥០ក្រាមលើផ្ទៃដី ១០-១៥ ម៉ែត្រការេ មុននឹងបាចត្រូវស្រោចទឹកឱ្យជោគជាមុន ។

## ៥. ការបន្សុទ្ធពូជ និងទុកពូជ

ការបន្សុទ្ធពូជ គឺដើម្បីឱ្យការផលិត និងរក្សាពូជស្ពៃចង្កឹះនៅតែសុទ្ធល្អ អ្នកដាំដុះត្រូវអនុវត្តន៍ដូចជា :

- ស្ទូងស្ពៃចង្កឹះឱ្យរង្វើលចន្លោះគុម្ព៤០x៤០ស.ម នៅពេលស្ពៃកំពុងលូតលាស់ត្រូវពិនិត្យពណ៌នៃធាងស្លឹក ។ទ្រង់ទ្រាយធាងស្លឹកមូលទ្រវែង ធាងពណ៌បៃតងខ្ចីធំផ្នែកខាងគល់ ផ្នែកកធាងស្លឹករលោង ឈរត្រង់ អាយុចេញផ្កា ក្រោយស្ទូងបានចំនួនពី ៣០-៤០ថ្ងៃ ចំនួនធាងសរុបពី ១៤-១៦ធាង ។ បន្ទាប់មកទៀតត្រូវដាក់ស្លាកសំគាល់របស់ដើមនីមួយៗដោយឡែកពីគ្នា ។

- នៅពេលស្ពៃចង្កឹះចាប់ផ្តើមចេញផ្កាដំបូងត្រូវបន្ថែមជី ១៥.១៥.១៥ ចំនួន២៥០-៣០០ក្រាម លើផ្ទៃដី ១០-១៥ម[២] នៅតាមចន្លោះគុម្ព ហើយស្រោចទឹកឱ្យជោគជារៀងរាល់ថ្ងៃរហូតដល់ផ្លែស្ពៃចាប់ផ្តើមទុំបានប្រមាណ ៥០% នៃចំនួនផ្លែក្នុងស្នែងទើបផ្អាកការស្រោចទឹក ។

## ៦. ការប្រមូលផល

ការប្រមូលផលសំរាប់ធ្វើបន្លែ គេអាចធ្វើការប្រមូលផលបាននៅពេលស្ពៃអាយុក្រោម១ខែ តែចំពោះការប្រមូលផលសំរាប់ទុកពូជគឺ ត្រូវច្រូតយកដើមស្ពៃមកហាលថ្ងៃឱ្យស្ងួត បន្ទាប់មកធ្វើការបោកបែនសំអាតគ្រាប់ ហើយហាលថ្ងៃឱ្យស្ងួតរយៈពេល ២-៣ ថ្ងៃទើបច្រកចូលដប កញ្ចប់ក្រដាស់ ឬ កញ្ចប់ក្រដាស់អាលុយមីញ៉ូមបិទជិតហើយរក្សាទុកនៅកន្លែងដែលមានអាកាសធាតុត្រជាក់ធម្មតា ហាត្រូវកំដៅថ្ងៃនិងសើម ។ ដប និងកញ្ចប់នីមួយៗត្រូវតែដាក់ឈ្មោះឱ្យបានត្រឹមត្រូវ ។

**<u>ការទុកដាក់ពូជ</u> :** ដើម្បីឱ្យគ្រាប់ពូជល្អ រក្សាដំណុះបានយូរខែ គ្រាប់ពូជត្រូវមានសំណើមយ៉ាងតិចចន្លោះពី ១៣-១៤ %ពូជដែលរក្សាទុកបានយូរ មិនត្រូវហាលនៅក្រោមកំដៅថ្ងៃផ្ទាល់ឡើយគឺត្រូវហាលក្រោមកំដៅដែលមានសំណាញ់រាំងការពារកំដៅ ។ ជាពិសេសអ្នកត្រូវហាលនៅក្រោមខ្យល់ស្ងួត ។ ឧបករណ៍ទុកដាក់ពូជប្រភេទសម្ភារៈមិនចម្លងសំណើមដូចជា : ដប កែវបិទជិតក្រដាសអាលុយមីញ៉ូម ។ ក្រោយពីច្រកហើយត្រូវបិទភ្ជិតមាត់ភ្លាម ហើយយកទៅរក្សាទុកក្នុងកន្លែងដែលមានកំដៅថេរល្អ ស្ងួត ពន្លឺថ្ងៃមិនអាចចាំងចូលបាន ។




រាជធានីភ្នំពេញ, ថ្ងៃទី ខែមីនា ឆ្នាំ២០១២

**នាយកដ្ឋានសាកវប្បកម្មនិងដំណាំរួចផ្សំ**